ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលព្រៃឈើ

កម្មវិធីព្រៃឈើជាតិ

# កំរងរបាយការណ៍

# ស្តីពីលទ្ធផលនៃ

# សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈអំពីកម្មវិធីព្រៃឈើជាតិ

# អធិការដ្ឋានរដ្ឋបាលព្រៃឈើខាងត្បូងបឹងទន្លេសាប

(ខេត្ត ពោធិ៍សាត់ ថ្ងៃទី ១៩-២០ ខែ មីនា ឆ្នាំ ២០០៩)

The Proceeding of
Public Consultation on National Forest Programme
Southern Tonlesab Lake FA Inspecotrate

រៀបចំចងក្រងដោយ លោក ឡុង ម៉ុង

អ្នកជំនួយការបច្ចេកទេសសិក្ខាសាលា

# មាតិការឿង


## ១. របាយការណ៍សង្ខេបលទ្ធផលនៃសិក្ខាសាលា

## ២. តារាងឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី ១ : កម្មវិធីសិក្ខាសាលា
- ឧបសម្ព័ន្ធទី ២ : សន្ទរកថារបស់ឯកឧត្តមអភិបាលរងខេត្ត ពោធិ៍សាត់
- ឧបសម្ព័ន្ធទី ៣ : សេចក្តីសង្ខេបកម្មវិធីទី ៣ : ការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និងអភិបាលកិច្ច
- ឧបសម្ព័ន្ធទី ៤ : របាយការណ៍លទ្ធផលសិក្ខាសាលា
- ឧបសម្ព័ន្ធទី ៥ : សេចក្តីសង្ខេបបទបង្ហាញលទ្ធផលក្រុមពិភាក្សា
- ឧបសម្ព័ន្ធទី ៦ : រូបថតសកម្មភាពសិក្ខាសាលា
- ឧបសម្ព័ន្ធទី ៧ : សំណួរ-ចម្លើយដែលលើកឡើងក្នុងសិក្ខាសាលា
- ឧបសម្ព័ន្ធទី ៨ : សេចក្តីថ្លែងការណ៍របស់សហគមន៍ខាងត្បូងបឹងទន្លេសាប
- ឧបសម្ព័ន្ធទី ៩ : បញ្ជីឈ្មោះសមាជិកក្រុមពិភាក្សា
- ឧបសម្ព័ន្ធទី ១០ : បទបង្ហាញនៃកម្មវិធីព្រៃឈើជាតិទាំង ៦
- ឧបសម្ព័ន្ធទី ១១ : បទបង្ហាញលទ្ធផលតាមក្រុមពិភាក្សា

# របាយការណ៍សង្ខេបពីលទ្ធផលនៃសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈស្តីពីកម្មវិធីព្រៃឈើជាតិ នៅអធិការដ្ឋានរដ្ឋបាលព្រៃឈើខាងត្បូងបឹងទន្លេសាប

ខេត្ត ពោធិ៍សាត់, ថ្ងៃទី ១៩-២០ ខែ មីនា ឆ្នាំ ២០០៩

រដ្ឋបាលព្រៃឈើ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ រួមជាមួយបណ្តាភាគីពាក់ព័ន្ធបានរួមគ្នារៀបចំសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិដែលជាជំហានសំខាន់មួយឆ្ពោះទៅរកការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។ កម្មវិធីនេះមានកម្មវត្ថុឆ្លើយតបតំរូវការជាលក្ខណៈមូលដ្ឋាន ថ្នាក់ជាតិ និង សាកល ដោយផ្តល់ឯកសារមានតម្លាភាព និង មានចំណងទាក់ទងគ្នាជាយុទ្ធសាស្ត្រមួយដើម្បីធ្វើផែនការ គ្រប់គ្រង ប្រើប្រាស់ ការពារ និង បង្កើនធនធានព្រៃឈើ បំពេញសេចក្តីត្រូវការដល់មនុស្សជំនាន់បច្ចុប្បន្ន និង ជំនាន់ក្រោយៗទៀត។

ក្រុមការងារមួយដែលមានតំណាងពីរដ្ឋបាលព្រៃឈើ ក្រសួងពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល វិស័យឯកជនបានរួមគ្នារៀបចំសេចក្តីព្រាងកម្មវិធីព្រៃឈើដើម្បីគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ កម្មវិធីព្រៃឈើជាតិជាឯកសារគោលមួយដែលក្នុងនោះមានកម្មវិធីចំនួន ៦ : ១). កម្មវិធីកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និង ការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ២). កម្មវិធីគ្រប់គ្រងធនធានព្រៃឈើជាតិ និង ការអភិរក្ស ៣). កម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ច ៤). កម្មវិធីសហគមន៍ព្រៃឈើជាតិ ៥).កម្មវិធីអភិវឌ្ឍសមត្ថភាព និង ការស្រាវជ្រាវ ៦). កម្មវិធីហិរញ្ញប្បទានដើម្បីការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។

សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈអំពីកម្មវិធីព្រៃឈើជាតិ ត្រូវបានរៀបចំដោយអធិការដ្ឋានរដ្ឋបាលព្រៃឈើ និងមានឧបត្ថម្ភផ្នែកថវិកាពីដៃគូអភិវឌ្ឍន៍មានដានីដា និង FAO។ គោលបំណងនៃសិក្ខាសាលាគឺ កែលំអឯកសារព្រាងកម្មវិធីព្រៃឈើជាតិឱ្យកាន់តែល្អប្រសើរ បង្កើនការផ្សព្វផ្សាយ និង ការយល់ដឹងអំពីកម្មវិធីព្រៃឈើជាតិ ប្រមូលមតិ, ទស្សនៈ និង យោបល់ ពីអ្នកពាក់ព័ន្ធនានានៅថ្នាក់មូលដ្ឋាន បង្កើនការគាំទ្រ និងការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍនិងការអនុវត្តកម្មវិធីព្រៃឈើជាតិ និង តូវបានរៀបចំនៅខេត្តពោធិ៍សាត់ក្នុងមជ្ឈមណ្ឌលអភិវឌ្ឍន៍ **ហ៊ុន រ៉ានី ហ៊ុន សែន** នៅថ្ងៃទី ១៩-២០ ខែ មីនា ឆ្នាំ ២០០៩។

សិក្ខាសាលាពិគ្រោះយោបល់នេះត្រូវបានរៀបចំឡើងក្រោមអធិបតីភាពឯកឧត្តម **ជា សំអាង** អនុប្រធានរដ្ឋបាលព្រៃឈើ និង សមាជិកគណៈអធិបតីជាអភិបាលរងមកពីខេត្ត កំពង់ស្ពឺ កំពង់ឆ្នាំង កណ្តាល ពោធិ៍សាត់ និង បាត់ដំបង ព្រមទាំងសមាជិកមកពីអង្គភាពពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន សហគមន៍មូលដ្ឋាន សរុបទាំងអស់ ចំនួន ១៥៨ នាក់។

ក្នុងសន្ទរកថាបើកសិក្ខាសាលា ឯកឧត្តម **ឆឺ គឹមតុក** អភិបាលរងខេត្តពោធិ៍សាត់ បានបញ្ជាក់អំពីសារៈសំខាន់នៃព្រៃឈើចំពោះជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន និង ផលប៉ះពាល់ពីការបាត់បង់ព្រៃឈើ (ឧបសម្ព័ន្ធ ២) ហើយ ឯកឧត្តម **ខាំ សំអាន** អនុប្រធានរដ្ឋបាលព្រៃឈើបានថ្លែងថា យើងបានទទួលមរតកធនធានព្រៃឈើពីបុព្វបុរសរបស់យើង ហើយយើង ក៏ជាស្ពានចម្លងមរតកទាំងនេះទៅកូនចៅជំនាន់ក្រោយៗទៀត ពួកគេទាំងអស់មិនអាចរស់នៅដោយគ្មានព្រៃឈើបានទេ។ ឯកឧត្តមក៏បង្ហាញក្តីព្រួយបារម្ភដែលនៅលើពិភពលោកសព្វថ្ងៃកំណើនធនធានព្រៃឈើមិនសមាមាត្រនឹងកំណើនមនុស្ស។

សិក្ខាសាលារយៈពេលពីរថ្ងៃ ត្រូវបានរៀបចំដោយថ្ងៃទី ១ សំរាប់ការធ្វើបទបង្ហាញពីអ្នកចងក្រងកម្មវិធីទាំង ៦ និង អនុកម្មវិធីមួយចំនួនទៀត ហើយបន្ទាប់ពីបទបង្ហាញនៃកម្មវិធីនីមួយៗមានសំណួរ-ចម្លើយពិភាក្សាតាមកម្មវិធី និង ចុងបញ្ចប់នៃកម្មវិធីថ្ងៃទី ១ មានវេទិការសំរាប់ការសួរ-ឆ្លើយរយៈពេល ១ ម៉ោង និង ៣0នាទីបន្ថែមទៀតទៅកម្មវិធីទាំង ៦។ ថ្ងៃទី ២ នៃពិធីសិក្ខាសាលា គឺសំរាប់ការបែងចែកក្រុមពិភាក្សាតាមកម្មវិធីទាំង ៦ ដោយសិក្ខាកាមទាំងអស់បានចុះឈ្មោះពិភាក្សា តាមចំណង់ចំណូលចិត្ត បទពិសោធន៍ និងការងារចំពោះរបស់ខ្លួន ហើយបន្ទាប់ពីការពិភាក្សារួចតំណាងក្រុមនីមួយៗដែលសុទ្ធតែមកពីសហគមន៍មូលដ្ឋានបានធ្វើបទបង្ហាញពីលទ្ធផលរបស់ក្រុមខ្លួនព្រមទាំងបានឆ្លើយសំណួរដែលបានលើកឡើងយ៉ាងក្បោះក្បាយ។

ដំណើរការនៃសិក្ខាសាលាប្រព្រឹត្តិទៅមានភាពរលូន ដោយមានសិក្ខាកាមសរុបចំនួន ១៥២ នាក់បានចុះឈ្មោះតាមក្រុម ឬកម្មវិធីពិភាក្សានីមួយៗ (ឧបសម្ព័ន្ធ ៩) ក្រោយពេលពិភាក្សាបានលទ្ធផលរួចហើយក្រុមនីមួយៗបានឡើងធ្វើបទបង្ហាញ និង ឆ្លើយសំណួរទាក់ទងនឹងកម្មវិធីរបស់ខ្លួនដោយមានសមាជិកក្រុម និង អ្នកចងក្រងកម្មវិធីជួយសំរបសំរួលយ៉ាងអស់ពីលទ្ធភាពធ្វើឱ្យបរិយាកាសនៃ សិក្ខាសាលាមានសភាពផុសផុលយ៉ាងខ្លាំង (ឧបសម្ព័ន្ធ ៧ និង ១១)។ ក្រៅពីនោះក៏មានសេចក្តីថ្លែងការណ៏របស់សហគមន៍មូលដ្ឋានអំពីសិក្ខាសាលានេះផងដែរ (ឧបសម្ព័ន្ធ ៥)។

សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈស្តីពីកម្មវិធីព្រៃឈើជាតិដែលបានធ្វើនៅថ្នាក់មូលដ្ឋាន ហើយ មានភាគីពាក់ព័ន្ធនៅមូលដ្ឋានចូលរួមមានសារៈសំខាន់ខ្លាំងណាស់ព្រោះជាឱកាសដែលបណ្តាភាគីពាក់ព័ន្ធបានចូលរួមចំណែកបញ្ចេញមតិ យោបល់ និង ទស្សនៈក្នុងការរៀបចំឯកសារផែនការគ្រប់គ្រងព្រៃឈើរយៈពេលវែង។ សិក្ខាសាលាបានប្រព្រឹត្តិទៅប្រកបដោយបរិយាកាសយកចិត្តទុកដាក់ ស្និទ្ធស្នាល និង ការពិភាក្សាពោរពេញទៅដោយផ្លែផ្កា ហើយមតិ យោបល់ ទស្សនៈដែលលើកឡើងក្នុងឱកាសសិក្ខាសាលា ព្រមទាំងសេចក្តីថ្លែងការណ៏រួមគ្នារបស់សហគមន៍នៅតំបន់ខាងត្បូងបឹងទន្លេសាបគួរតែត្រូវបានយកទៅពិចារណារដោយក្រុមការងាររៀបចំកម្មវិធីព្រៃឈើជាតិ ដើម្បីដាក់បញ្ចូលទៅក្នុងឯកសារកម្មវិធីព្រៃឈើទៅតាមស្ថានភាព និង ចំណងទាក់ទងរបស់វាដើម្បីរួមចំណែកក្នុងការកែលំអឯកសារកម្មវិធីព្រៃឈើជាតិឱ្យរឹតតែប្រសើរថែមទៀត។

# សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ

**ទីកន្លែង: មជ្ឈមណ្ឌលអភិវឌ្ឍន៍ ប៊ុន រ៉ានី ហ៊ុន សែន ខេត្តពោធិ៍សាត់ ថ្ងៃទី ១៩-២០ ខែមិនា ឆ្នាំ២០០៩**

| កាលបរិច្ឆេទ | ពេលវេលា | កម្មវត្ថុ | វិធីសាស្ត្រ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ១៩ មិនា | ០៨:០០-០៨:៣០ | ចុះឈ្មោះ | ចុះហត្ថលេខា | អ្នកជំនួយការ |
| | ០៨:៣០-០៩:០០ | - គោរពទង់ជាតិ<br>- សុន្ទរកថាស្វាគមន៍<br>- សុន្ទរកថាបើក | មតិ | - អ្នកសំរបសំរួល<br>- ឯ.ឧ. **ទី គឹមតុក** អភិបាលរងខេត្តពោធិសាត់<br>- ឯ.ឧ. **ជា សំអាង** អនុប្រធានរដ្ឋបាលព្រៃឈើ |
| | ០៩:០០-១០:០០ | សេចក្តីផ្តើម<br>- គោលបំណង និងលទ្ធផលរំពឹងទុកពីសិក្ខាសាលា<br>- ដំណើរការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិ | បទបង្ហាញ | បណ្ឌិត សុខ ហេង |
| | ១០:០០-១០:៣០ | **អាហារសំរន់** | | |
| | ១០:៣០-១០:៤០ | បទបង្ហាញអំពី ឯកសារគោលកម្មវិធីព្រៃឈើជាតិ | បទបង្ហាញ | បណ្ឌិត សុខ ហេង |
| | ១០:៤០-១១:០០ | បទបង្ហាញកម្មវិធីទី១: ការកំណត់ព្រំប្រទល់ | បទបង្ហាញ | លោក មាស មករា និង លោក លាង ហ៊ន |
| | ១១:០០-១១:៤០ | បទបង្ហាញកម្មវិធីទី២: ការគ្រប់គ្រង និងអភិរក្សព្រៃឈើ | បទបង្ហាញ | លោក ឃន សារ៉េត លោក សា មករា លោក ហង់ ស៊ុនត្រា លោក អួន សំអុល លោក ឈាង ដានី |
| | ១១:៤០-១២:០០ | បទបង្ហាញកម្មវិធីទី៣: ការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ | បទបង្ហាញ | លោក សួន សុវណ្ណ |
| | ១២:០០-១៣:០០ | **អាហារថ្ងៃត្រង់** | | |
| | ១៣:០០-១៣:២០ | បទបង្ហាញកម្មវិធីទី៤: សហគមន៍ព្រៃឈើ | បទបង្ហាញ | លោក ឡាវ សេដ្ឋាផល |
| | ១៣:២០-១៣:៤០ | បទបង្ហាញកម្មវិធីទី៥: ការកសាងសមត្ថភាព និងអភិវឌ្ឍការស្រាវជ្រាវ | បទបង្ហាញ | លោក ចាន់ សុផល លោក ប៊ុន រ៉ាដា លោក នុព សុធា លោក សរិទ្ធ វណ្ណា |
| | ១៣:៤០-១៤:០០ | បទបង្ហាញកម្មវិធីទី៦: ហិរញ្ញវត្ថុព្រៃឈើ | បទបង្ហាញ | លោក ម៉ា សុខថា |
| | ១៤:០០-១៥:៣០ | សំនួរ និងចំលើយ | | លោក ឡុង ប៊ុង និងអ្នកចងក្រងកម្មវិធី |
| | ១៥:៣០-១៦:០០ | **អាហារសំរន់** | | |
| | ១៦:០០-១៧:៣០ | ពិភាក្សាតាមក្រុម | ប្រមូលមតិ | អ្នកបច្ចេកទេស និងអ្នកចងក្រង |
| ២០ មិនា | ០៨:០០-១០:០០ | ពិភាក្សាតាមក្រុម | ប្រមូលមតិ | អ្នកបច្ចេកទេស និងអ្នកចងក្រង |
| | ១០:០០-១០:៣០ | **អាហារសំរន់** | | |
| | ១០:០០-១២:០០ | ចែករំលែកលទ្ធផលពីក្រុមពិភាក្សា | ប្រមូលមតិ | អ្នកបច្ចេកទេស និងអ្នកចងក្រង |
| | ១២:០០-១៣:៣០ | **អាហារថ្ងៃត្រង់** | | |
| | ១៣:៣០-១៥:០០ | - -របាយការណ៍បូកសរុប<br>- មតិចាប់អារម្មណ៍របស់អ្នកចូលរួម<br>- សុន្ទរកថាបិទអង្គសិក្ខាសាលា | | លោក ពិន ផានី<br>លោក សៅ ដារឿន<br>ឯ.ឧ. ទីម ស៊ីផា |
| | ១៥:០០-១៥:៣០ | **អាហារសំរន់** | | |

# សុន្ទរកថាស្វាគមន៍

## របស់ឯកឧត្តម ឌី គឹមតុក អភិបាលរងខេត្តពោធិសាត់ ថ្លែងក្នុងសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ ប៊ុន រ៉ានី ហ៊ុន សែន ពោធិសាត់

(ខេត្តពោធិសាត់, ថ្ងៃទី ១៩ ខែមិនា ឆ្នាំ២០០៩)

***- សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ***

***-សូមគោរពឯកឧត្តម ជា សំអាង ទីប្រឹក្សានៃទីស្តីការគណៈរដ្ឋមន្ត្រី និងជាអនុប្រធានរដ្ឋបាលព្រៃឈើ***

***-សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និង សមាជិក សមាជិកា នៃអង្គសិក្ខាសាលា ជាទីមេត្រី !***

ជាបឋម ក្នុងនាមអាជ្ញាធរខេត្ត និងក្នុងនាមខ្លួនខ្ញុំព្រះករុណា ខ្ញុំ សូមសំដែងអំណរព្រះគុណ និងអរគុណយ៉ាងជ្រាលជ្រៅ និងស្មោះស្ម័គ្រ និង សូមគោរពស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះព្រះថេរានុថេរៈគ្រប់ព្រះអង្គ ឯកឧត្តម អនុប្រធានរដ្ឋបាលព្រៃឈើ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានឆ្លៀតឱកាសដ៏មមាញឹក និងមានតម្លៃដើម្បីមកចូលរួមជាភ្ញៀវកិត្តិយស និងជាសិក្ខាកាមក្នុងអង្គសិក្ខាសាលាជាតិពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិដ៏មានសារៈសំខាន់នាពេលនេះ។ វត្តមានដ៏ឧត្តុង្គឧត្តម និង ច្រើនកុះកររបស់ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាថ្ងៃនេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ ក្នុងការចូលរួមស្វែងយល់អំពីវិស័យព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំព្រះករុណា ខ្ញុំមានមោទនៈភាព និងសេចក្តីរីករាយជាពន្លឹក ដែលរដ្ឋបាលព្រៃឈើបានសំរេចជ្រើសរើសយកខេត្តពោធិសាត់ ដែលជាខេត្តសំបូរទៅដោយធនធានព្រៃឈើ (ក្នុងភូមិភាគខាងត្បូងបឹងទន្លេសាបដែលមានខេត្តប៉ៃលិន បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល រាជធានីភ្នំពេញ និង ខេត្តពោធិសាត់យើងខ្ញុំព្រះករុណា) សំរាប់ជាកន្លែងរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ ក្នុងគោលបំណងប្រមូលមតិ និង យោបល់ពីសំណាក់ភាគីពាក់ព័ន្ធនានា ដែលមកពីបណ្តាមូលដ្ឋាននៃភូមិភាគនេះ ដើម្បីកែលំអសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិនេះឱ្យក្លាយជាយុទ្ធសាស្ត្រជាតិប្រកបដោយតម្លាភាព និង ប្រសិទ្ធិភាពខ្ពស់ ដើម្បីរៀបចំផែនការការគ្រប់គ្រង ការប្រើប្រាស់ ការការពារ និង ការទាញយកផលប្រយោជន៍ពីធនធានព្រៃឈើដោយនិរន្តរភាព សំរាប់សង្គមមនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយៗទៀត។ ខ្ញុំព្រះករុណា ខ្ញុំយល់ឃើញថាអង្គសិក្ខាសាលានេះមានសារៈប្រយោជន៍ណាស់ ដើម្បីផ្សព្វផ្សាយ និង ពន្យល់ពីកម្មវិធីសំខាន់ៗសំរាប់អនុវត្តន៍ និង បង្កើនការចូលរួមពីបណ្តាភាគីពាក់ពន្ធ័នៅមូលដ្ឋាន ដើម្បីជំរុញការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រនៅជនបទ ដែលជាទិសដៅដ៏សំខាន់មួយនៃផែនការយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។

***-ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ***

***-ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ជាទីគោរព***

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណា ខ្ញុំសូមទូលប្រគេន និងជំរាបជូនអង្គសិក្ខាសាលាជ្រាបជាពតិមានគ្រួសៗ អំពីស្ថានភាពព្រៃឈើនៅខេត្តពោធិសាត់ ចំនួនប្រជាពលរដ្ឋ និងមុខរបរសំខាន់ៗរបស់ពលរដ្ឋនៃខេត្តពោធិសាត់យើង ខ្ញុំព្រះករុណា សំរាប់ជាមូលដ្ឋានបន្ថែមក្នុងការពិភាក្សា និងចូលរួមផតល់យោបល់។ ខេត្តពោធិសាត់មានផ្ទៃដីសរុប ១.១៥៨.៩៩១ហិកតា ក្នុងនោះមានផ្ទៃដីព្រៃឈើចំនួន ៨៨៥.៤៤០ហិកតា ស្មើនឹង ៧៦.៤២ភាគរយ ( រព ២០០៨) និងមានប្រជាពលរដ្ឋចំនួន ៤២៦.៧៥៨នាក់ ស្មើនឹង ៨៣.១៥៣គ្រួសារ ដែលភាគច្រើនជាកសិកររស់នៅពឹងផ្អែកស្ទើរតែទាំងស្រុងលើធនធានព្រៃឈើ និងធនធានជលផល។ ដូច្នេះការបាត់ធនធានព្រៃឈើ និងព្រៃលិចទឹកបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋយើង ក៏ដូចប្រជាជនក្នុងតំបន់ផងដែរ។ កន្លងមកព្រៃឈើក្នុងខេត្តពោធិសាត់ក៏ដូចខេត្តផ្សេងៗ ទទួលរងនូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរតាមរយៈការធ្វើអាជីវកម្មអនាធិបតេយ្យ ការតាំងលំនៅដ្ឋានភូមិករថ្មីៗក្នុងតំបន់ព្រៃឈើ ការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើជាកម្មសិទ្ធិ។

អនុវត្តតាមអនុសាសន៏ និង ការដឹកនាំដ៏ត្រឹមត្រូវ និង ឈ្លាសវៃបំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្រ្តីនៃរាជរដ្ឋាភិបាលកម្ពុជា និងអនុវត្តបទបញ្ជាលេខ ០១ បប ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៤ ស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ និងបទបញ្ជាលេខ ០២ បប ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យ លើការប្រើប្រាស់រណារយន្តកាត់-អារឈើ អាជ្ញាធរខេត្តពោធិសាត់ សហការជាមួយបណ្តាស្ថាប័នពាក់ពន្ធ័ ជាពិសេសរដ្ឋបាលព្រៃឈើបានធ្វើការទប់ស្កាត់ បង្ក្រាបអំពើអនាធិបតេយ្យព្រៃឈើគ្រប់ប្រភេទដោយទទួលលទ្ធផលជាបន្តបន្ទាប់មានជាអាទិ៍ : អនុគណៈកម្មធិការខេត្តពោធិសាត់ដើម្បីទប់ស្កាត់ លុបបំបាត់ បង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើជាកម្មសិទ្ធិ បានស្រង់ស្ថិតិដីព្រៃឈើដែលបានកាប់រានដោយខុសច្បាប់ចំនួន ១៣.៦០១ហិកតា ដកហូតដីព្រៃឈើមកទុកជាសម្បត្តិរដ្ឋវិញបានចំនួន ៣.៤០៥ហិកតា ស្រង់ស្ថិតិរណារយន្តកាត់-អារឈើចំនួន ២០០គ្រឿង ដកហូតរណារយន្តកាត់-អារឈើចំនួន ៦១គ្រឿង និង កំពុងបន្តធ្វើការស្រាវជ្រាវដើម្បីចាត់វិធានការជាក់ស្តែង។

បន្ថែមលើសកម្មភាពខាងលើ យើងមានកម្មវិធីអភិរក្សព្រៃឈើតំបន់ជួរភ្នំក្រវាញភាគកណ្តាលនៃអង្គការ CI អង្គការ FFI អង្គការក្រៅរដ្ឋាភិបាលមួយចំនួនទៀត ដែលបានធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន និង សហគមន៏ក្នុងសកម្មភាពអភិរក្សធនធានព្រៃឈើ សត្វព្រៃ ជីវៈចំរុះ និង បង្កើតសហគមន៏ព្រៃឈើ ដែលបានរួមចំណែកយ៉ាងច្រើនក្នុងការការពារ អភិរក្សធនធានធម្មជាតិឱ្យនៅគង់វង្ស រួមចំណែកកាត់បន្ថយភាពក្រីក្រនៅជននៃប្រទេសយើង។

***-ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ***

***-ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ជាទីគោរព***

ជាថ្មីម្តងទៀតខ្ញុំព្រះករុណា ខ្ញុំសង្ឃឹមថា អង្គសិក្ខាសាលានាថ្ងៃនេះ នឹងផ្តល់អត្ថប្រយោជន៍យ៉ាងសំខាន់ក្នុងការចូលរួមមតិកែលំអសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិនេះ ក៏ដូចជាការចូលរួមការពារធនធានព្រៃឈើនៅកម្ពុជាឱ្យបានកាន់តែប្រសើរ និង សូមព្រះថេរានុថេរៈគ្រប់ព្រះអង្គ ឯកឧត្តម អស់លោក លោកស្រីទាំងអស់ចូលរួមស្វែងយល់ពិភាក្សា និង ផ្តល់មតិឱ្យបានផុលផុសដើម្បីឱ្យកម្មវិធីព្រៃឈើជាតិនេះ ឆ្លើយតបទៅនឹងតំរូវការថ្នាក់មូលដ្ឋាន មានភាពស៊ីសង្វាក់ ព្រមទាំងមានការគាំទ្រដល់ផែនការអភិវឌ្ឍន៍ជាតិ និង គោលដៅសហសវត្សរបស់កម្ពុជាដែលប្តេជ្ញាថែរក្សាគំរបព្រៃឈើឱ្យបានចំនួន ៦០ភាគរយ នៅទូទាំងប្រទេសនាឆ្នាំ ២០១៥។

ជាទីបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងអំណរព្រះគុណ និងអំណរគុណចំពោះព្រះថេរានុថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ដែលបាននិមន្ត និងអញ្ជើញចូលរួមក្នុងអង្គសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិនាថ្ងៃនេះ។ សូមប្រសិទ្ធិពរប្រគេនព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមជូនពរឯកឧត្តម លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិទាំងអស់ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើកអង្គសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ ចាប់ពីពេលនេះតទៅ។

*សូមអរព្រះគុណ និងអរគុណ !*

## ៣. កម្មវិធីអនុវត្តច្បាប់ព្រៃឈើ និង អភិបាលកិច្ច

**ចំណុចអាទិភាព**

- ការអនុវត្តច្បាប់ព្រៃឈើ
- ការការពារជាមុននូវបទល្មើសព្រៃឈើ
- បង្កើនការយល់ដឹង
- អភិបាលកិច្ចព្រៃឈើ

**កម្មវិធីនេះស្របនឹងទស្សនៈទានកម្មវិធីព្រៃឈើជាតិយ៉ាងដូចម្តេច?**

- ព្រៃឈើជាសម្បត្តិសាធារណៈ សំរាប់មនុស្សជំនាន់នេះ និង ជំនាន់ក្រោយៗទៀត
- ប្រជាពលរដ្ឋភាគច្រើនរស់នៅពឹងផ្អែកលើធនធានព្រៃឈើ
- បទល្មើសព្រៃឈើ កាប់រានដីព្រៃឈើ ធ្វើឱ្យធនធានព្រៃឈើថយចុះ បំផ្លាញបរិស្ថាន ជីវចំរុះ ការកើនកំដៅផែនដី បាត់បង់ចំណូលថវិកាជាតិ
- កម្មវិធីអនុវត្តច្បាប់ព្រៃឈើ និង អភិបាលកិច្ច មានគោលដៅស្របនឹងទស្សនៈទានកម្មវិធីព្រៃឈើជាតិដោយធានាបាននូវការរៀបចំព្រៃឈើប្រកបដោយនិរន្តរភាព។

**កម្មវិធីនេះស្របនឹងគោលបំណងកម្មវិធីព្រៃឈើយ៉ាងដូចម្តេច?**

- លុបបំបាត់ការកាប់ឈើអនាធិបតេយ្យ ការកាន់កាប់ដីព្រៃឈើខុសច្បាប់
- ជំរុញ និង បង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលរស់នៅពឹងផ្អែកលើធនធានព្រៃឈើ
- ជំរុញឱ្យមានការប្រភពផ្គត់ផ្គង់ផល-អនុផលព្រៃឈើស្របច្បាប់ និង មានលក្ខណៈប្រកួតប្រជែង
- ផ្សព្វផ្សាយ ពង្រឹងការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការអនុវត្តច្បាប់ និង ទស្សនៈទូទៅអំពីអភិបាលកិច្ចព្រៃឈើ

**គោលបំណងនៃកម្មវិធីអនុវត្តច្បាប់ព្រៃឈើ និង អភិបាលកិច្ច**

គោលបំណងនៃកម្មវិធីនេះធានាអភិបាលកិច្ច និង អនុវត្តច្បាប់មានតម្លាភាព ស្មើភាព និង យុត្តិធម៌។

- លុបបំបាត់សកម្មភាពល្មើសច្បាប់គ្រប់ប្រភេទក្នុងដែនព្រៃឈើ
- ធានានូវការរៀបចំ និង អនុវត្ត ច្បាប់ គោលនយោបាយ លិខិតបទដ្ឋាន
- ជំរុញអភិបាលកិច្ចល្អ ដោយបង្កើនសមត្ថភាពខាងដោះស្រាយទំនាស់
- ឆ្ពោះទៅការប្រើប្រាស់ធនធានព្រៃឈើដោយនិរន្តរភាពសិទ្ធិ និង កាតព្វកិច្ច
- ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ព្រៃឈើ និង អភិបាលកិច្ច
- ធ្វើឱ្យប្រសើរនូវការប្រើប្រាស់ឈើប្រកបដោយនិរន្តរភាព គោរពសិទ្ធិ និង កម្មសិទ្ធិសាធារណៈ
- វិធីសាស្ត្រមានប្រសិទ្ធភាពក្នុងប្រតិបត្តិការស៊ើបអង្កេត តាមដាន ទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ
- បង្កើនចំណេះដឹងជាសាធារណៈអំពីច្បាប់ និង លិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើដើម្បីឱ្យមានការគោរព និងអនុវត្តច្បាប់

## យុទ្ធសាស្រ្តអនុវត្តកម្មវិធីអនុវត្តច្បាប់ព្រៃឈើ និង អភិបាលកិច្ច

កម្មវិធីនេះមានរយៈពេលវែង និងត្រូវការនូវការប្តេជ្ញាចិត្តខ្លាំងក្លាពីស្ថាប័នរដ្ឋដែលពាក់ព័ន្ធ

- o កិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និង អង្គការក្រៅរដ្ឋាភិបាល។ ជំហានសំខាន់គឺ ការបង្កើតក្រុមការងារអន្តរស្ថាប័នដែលនឹងកំណត់អត្តសញ្ញាណបញ្ហាដែលនាំឱ្យកើតមានបទល្មើសព្រៃឈើ (បទឧក្រិដ្ឋព្រៃឈើ) ហើយរៀបចំយុទ្ធសាស្រ្តរឹងមាំមួយដោះស្រាយបញ្ហានេះ។
- o គ្រប់គ្រងដោះស្រាយទំនាស់ និង ជំរុញឱ្យមានតម្លាភាព និងភាពទទួលខុសត្រូវក្នុងវិស័យព្រៃឈើ។ រដ្ឋបាលព្រៃឈើនឹងគ្រប់គ្រងដោះស្រាយទំនាស់នានាដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើក្នុងកំរិតមីក្រូ (ជម្លោះរវាងបុគ្គលនឹងបុគ្គល និង ប្រជាពលរដ្ឋក្នុងសហគមន៍) និង ក្នុងកំរិតម៉ាក្រូ (ជម្លោះរវាងសហគមន៍ជាមួយអ្នកខាងក្រៅ ស្ថាប័នផ្សេងៗ និង ពួកឈ្មួញ)។
- o ធ្វើការសំរបសំរួលជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗដើម្បីរួមគ្នាអនុវត្តច្បាប់។ កម្មវិធីអនុវត្តច្បាប់ព្រៃឈើ និងអភិបាលកិច្ចមានគោលបំណងសំរបសំរួលជាមួយស្ថាប័នរដ្ឋាភិបាលផ្សេងៗដែលពាក់ព័ន្ធក្នុងការអនុវត្តច្បាប់ និង គោលនយោបាយនានាដែលពាក់ព័ន្ធ ទាំងក្នុងនិង ក្រៅវិស័យព្រៃឈើ។
- o បង្កើនអភិបាលកិច្ចខ្សែសង្វាក់តម្លៃឈើ ដើម្បីជំរុញទៅកាន់ទីផ្សារអន្តរជាតិធំៗ។ ដើម្បីជំរុញការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ឈើ រាជរដ្ឋាភិបាលនឹងពិចារណាការបង្កើតកិច្ចព្រមព្រៀងដៃគូស្ម័គ្រចិត្តជាមួយទីផ្សារសំខាន់ៗ ដូចជា អ៊ឺរ៉ុបជាដើម។ ផ្នែកសំខាន់នៃចំណុចនេះគឺរៀបចំប្រព័ន្ធធានារ៉ាប់រងផ្លូវច្បាប់មួយ ហើយជំហានដើម្បីអនុវត្តប្រព័ន្ធធានារ៉ាប់រងផ្លូវច្បាប់នេះរួមមាន៖
    - រៀបចំនិយមន័យច្បាស់លសាស់មួយអំពី ផលិតផលឈើស្របច្បាប់នៃប្រទេសកម្ពុជា
    - រៀបចំប្រព័ន្ធមួយជាក់លាក់ដើម្បីផ្ទៀងផ្ទាត់ ឯកតាគ្រប់គ្រងព្រៃឈើ ដែលស្របតាមនិយមន័យខាងលើ
    - ផ្តល់អាជ្ញាប័ណ្ណផលិផលឈើនាំចេញដើម្បីបញ្ជាក់ភាពស្របច្បាប់
    - ដាក់ឱ្យមានការតាមដានឯករាជ្យនៃប្រព័ន្ធធានារ៉ាប់រងផ្លូវច្បាប់នេះ
- o ជំរុញឱ្យមានវិញ្ញាបនប័ត្រសំរាប់អ្នកផលិតផល អនុផលព្រៃឈើ។ ការចេញវិញ្ញាប័ត្រ ជួយទប់ស្កាត់បទល្មើសព្រៃឈើហើយក៏ជួយលើកទឹកចិត្តអ្នករកទទួលទានស្របច្បាប់។
- o បង្កើនកិច្ចសហប្រតិបត្តិការជាអន្តរជាតិ និង ប្រទេសជិតខាងទប់ស្កាត់បទល្មើសព្រៃឈើ និង សត្វព្រៃឆ្លងដែន។
- o បង្កើតវិធានការដើម្បីធ្វើឱ្យមានតុល្យភាពរវាងតំរូវការ និង ការផ្គត់ផ្គង់ឈើ។ កម្មវិធីនេះនឹងមានការវិភាគពីសមត្ថភាពឧស្សាហកម្មឈើកម្ពុជា ដើម្បីឱ្យដឹងពីការផលិត និងការប្រើប្រាស់ ក្នុងគោលបំណងគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។

## អនុកម្មវិធី ១៖ កំណែទំរង់ច្បាប់ និង រដ្ឋបាល

### មធ្យោបាយអនុវត្ត

- o លើកទឹកចិត្តឱ្យមានការចូលរួមពីបណ្តាភាគីពាក់ព័ន្ធនានា ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល
- o ពង្រឹងកិច្ចសហការអន្តរក្រសួង /ស្ថាប័នតាមរយៈក្រុមការងារព្រៃឈើ និង បរិស្ថាន (TWG F&E) ដែលមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និង សង្គមស៊ីវិល

- សហការប្រតិបត្តិការជាមួយគណៈកម្មាធិការជាតិ និង អនុគណៈកម្មាធិការខេត្តដើម្បីទប់ស្កាត់ ការកាប់រាន ដុត ឈូសឆាយ ហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ ។
- សហការប្រតិបត្តិការជាមួយអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- លើកទឹកចិត្តឱ្យមានវិមជ្ឈការព្រៃឈើដើម្បីឱ្យមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋានក្នុងការគ្រប់គ្រង និង អភិរក្សធនធានព្រៃឈើ
- មនុស្សគ្រប់រូបក្នុងសង្គមត្រូវគោរពច្បាប់ មានសិទ្ធិស្មើគ្នាចំពោះច្បាប់
- ធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធតុលាការក្នុងការអនុវត្តច្បាប់ព្រៃឈើ ដោយរដ្ឋបាលព្រៃឈើជំរុញឱ្យមានការប្រជុំប្រចាំឆ្នាំជាមួយព្រះរាជអាជ្ញារាជធានី ខេត្តដើម្បីជំរុញការដោះស្រាយបទល្មើសព្រៃឈើ ។
- បន្តផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យ ស្ថិតិ បទល្មើសព្រៃឈើតាមរយៈទស្សនាវដ្ដីព្រៃឈើ ស្ថិតិព្រៃឈើ និង គេហទំព័ររបស់រដ្ឋបាលព្រៃឈើ
- បង្កើតផ្នែកទំនាក់ទំនងសាធារណៈដើម្បីផ្ដល់ពតិមាន ឯកសារ និង លិខិតបទដ្ឋាននានាដែលពាក់ព័ន្ធក្នុងវិស័យព្រៃឈើ
- បន្តចូលរួមចែករំលែកពតិមាន និង បទពិសោធន៍នានាតាមរយៈវេទិការថ្នាក់ជាតិ ថ្នាក់តំបន់ និង អន្តរជាតិ ។
- បង្កើតយន្តការប្រតិកម្មរហ័សចំពោះបទល្មើសព្រៃឈើនៅថ្នាក់កណ្ដាល និង មូលដ្ឋាន ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ពតិមាន និង ចាត់វិធានការចំពោះបទល្មើសព្រៃឈើដែលបានកើតឡើង និង ចុះផ្សាយតាមសាពតិមាននានា ។ បន្តទំនាក់ទំនង និង សហការល្អជាមួយយន្តការប្រតិកម្មរហ័សនៃទីស្ដីការគណៈរដ្ឋមន្ត្រី ។

## អនុកម្មវិធី ២. ពង្រឹងការអនុវត្តច្បាប់ ការតាមដាន និង រាយការណ៍ពីបទល្មើសព្រៃឈើ

**មធ្យោបាយអនុវត្ត**

- ផ្ដល់មធ្យោបាយ សំភារៈ ថវិកាគ្រប់គ្រាន់ដល់មន្ត្រីរដ្ឋបាលព្រៃឈើអនុវត្តច្បាប់ ។ រដ្ឋបាលព្រៃឈើមិនអាចបង្ក្រាបបទល្មើសព្រៃឈើដោយគ្មានសំភារៈមធ្យោបាយគ្រប់គ្រាន់ សំរាប់ប្រមូលពតិមាន ចងក្រងសំណុំរឿង និង ថែរក្សាវត្ថុតាង និង ការពារសុវត្ថិភាពផ្ទាល់ខ្លួនពេលប្រតិបត្តិការទេ ។
- បង្កើនប្រសិទ្ធភាពនៃយន្តការតាមដាន និង រាយការណ៍ពីករណីបទល្មើសព្រៃឈើ ។ ក្នុងនេះមាន : បង្កើតឱ្យមានការរួមគ្នារវាងរដ្ឋបាលព្រៃឈើ និង សហគមន៍មូលដ្ឋានការពារតំបន់អភិរក្សដែលសក្ដានុពលខ្ពស់, រៀបចំឱ្យមានសៀវភៅគោលការណ៍តូចអាចដាក់ហោប៉ាវ ឬយកតាមខ្លួនបាន និយាយអំពីរបៀបតាមដាន និង កត់ត្រាអំពីករណីបទល្មើសព្រៃឈើ, បន្តកត់ត្រាបញ្ចូលទិន្នន័យសំណុំរឿងបទល្មើសព្រៃឈើក្នុងប្រព័ន្ធកុំព្យូទ័រ និង ធ្វើបច្ចុប្បន្នភាព, សិក្សារូបថតពីលើអាកាសដើម្បីតាមដានការប្រែប្រួលគំរបព្រៃឈើ, បង្កើតប្រព័ន្ធមួយដែលអង្គការក្រៅរដ្ឋាភិបាលខាងបរិស្ថានឯករាជ្យ និង សង្គមស៊ីវិលអាចចូលរួមតាមដានបទល្មើសប្រៃឈើ ។
- បង្កើនប្រសិទ្ធភាពប្រព័ន្ធតុលាការពាក់ព័ន្ធនឹងសំណុំរឿងបទល្មើសព្រៃឈើ ។ បន្តកិច្ចសហការ និង បង្កើនប្រសិទ្ធភាពការងារជាមួយព្រះរាជអាជ្ញាអមតុលាការ, បណ្ដុះបណ្ដាលជំនាញចងក្រងសំណុំរឿងបទល្មើសព្រៃឈើដល់មន្ត្រីរដ្ឋបាលព្រៃឈើថ្នាក់មូលដ្ឋាន

និង សៀវភៅណែនាំដែលងាយយល់, សហការជាមួយស្ថាប័នពាក់ព័ន្ធបង្រ្កាបបទល្មើសព្រៃឈើទ្រង់ទ្រាយធំ ដូចជាការធ្វើអាជីវកម្មឈើអនាធិបតេយ្យ ការកាប់ រុករាន ដុតឈូឆាយដីព្រៃឈើវាតយកធ្វើកម្មសិទ្ធិ។

- o បង្កើនសហការជាមួយប្រទេសជាតិជិតខាង និង អន្តរជាតិទប់ស្កាត់បទល្មើសព្រៃឈើ សត្វព្រៃឆ្លងដែន។
- o បង្កើនកិច្ចសហការមានប្រសិទ្ធភាពជាមួយស្ថាប័នអនុវត្តច្បាប់ពាក់ព័ន្ធទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើ ដូចជា អគ្គនាយកដ្ឋានគយនិងរដ្ឋាករ, បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស នាយកដ្ឋានប្រឆាំងបទល្មើសសេដ្ឋកិច្ច កងយោធពលខេមរភូមិន្ទ។
- o សហការអនុវត្តឱ្យមានប្រសិទ្ធភាពដើម្បីទប់ស្កាត់ លុបបំបាត់ បង្ក្រាបបទល្មើស កាប់រាន ដុត ឈូសឆាយ ហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីព្រៃឈើធ្វើកម្មសិទ្ធិ។ ពង្រឹងយន្តការ និង បង្កើនសមត្ថភាពអនុគណៈកម្មធិការខេត្ត រាជធានី ក្រុមការងារថ្នាក់ស្រុកដកហូតដីព្រៃឈើដែលត្រូវបានកាប់រាន និង កាន់កាប់ដោយខុសច្បាប់, បង្កើតវេទិការដោះស្រាយទំនាស់ដីព្រៃឈើតាមរយៈការចរចារ, ផ្សព្វផ្សាយច្បាប់ និង លិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងការកាប់រាន និង កាន់កាប់ដីព្រៃឈើដោយខុសច្បាប់, ស្វែងរក និង ផ្តល់ថវិកាដល់អនុគណៈកម្មាធិការខេត្ត រាជធានី ដើម្បីសកម្មភាព ស្រាវជ្រាវ ស្រង់ស្ថិតិ ផ្ទៀងផ្ទាត់ និង ចេញដីកាដកហូតដីព្រៃឈើដែលកាន់កាប់ដោយខុសច្បាប់មកវិញ។

## អនុកម្មវិធី ៣. ប្រតិកម្មរហ័សចំពោះពត៌មានបទល្មើសព្រៃឈើ

### មធ្យោបាយអនុវត្ត

- o ក្រុមការងារនៅរដ្ឋបាលព្រៃឈើកណ្តាល។ រៀបចំប្រព័ន្ធការងារដើម្បីត្រួតពិនិត្យរាល់របាយការណ៍ដែលថ្នាក់មូលដ្ឋានផ្តល់ឱ្យ និង រៀបចំរបាយការណ៍ជូនប្រធានរដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ស្ថាប័នយន្តការប្រតិកម្មតាមករណីចាំបាច់, ទំនាក់ទំនងជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីផ្ទៀងផ្ទាត់ពត៌មានដែលចុះផ្សាយ, ក្នុងករណីចាំបាច់ចុះត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ពត៌មានដល់ទីកន្លែងជាក់ស្តែងដើម្បីស្វែងរកការពិត និង តម្លាភាព, បញ្ចូលពត៌មានក្នុងប្រព័ន្ធ កុំព្យូទ័រ និង គេហទំព័ររដ្ឋបាលព្រៃឈើ។
- o ក្រុមការងារនៅថ្នាក់មូលដ្ឋាន។ ត្រួតពិនិត្យពត៌មានដែលចុះផ្សាយតាមបណ្តាសារពត៌មាន, ចុះផ្ទៀងផ្ទាត់ជាក់ស្តែង ចាត់វិធានការទប់ស្កាត់ បង្ក្រាបជាមួយស្ថាប័នពាក់ព័ន្ធ, រៀបចំរបាយការណ៍បំភ្លឺជូនរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល។
- o បង្កើនកិច្ចសហការជាមួយប្រព័ន្ធសារពត៌មាន និង អ្នកផ្តល់ពត៌មាន។ រៀបចំឱ្យមានការប្រជុំរវាងរដ្ឋបាលព្រៃឈើ និងបណ្តាញសារពត៌មានដើម្បីបង្កើនកិច្ចសហការ, ផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋាននានាដល់សារពត៌មាន, បណ្តុះបណ្តាលជំនាញ ស៊ើបអង្កេតបទល្មើសព្រៃឈើ, រៀបចំទស្សនៈកិច្ចសិក្សាជាមួយអ្នកសារពត៌មានទៅកាន់កន្លែងដែលកើតមានបទល្មើសព្រៃឈើ, ស្វែងរកថវិកាសំរាប់សារពត៌មាន អ្នកផ្តល់ពត៌មាន ការចុះផ្សាយពត៌មានសំរាប់បង្កើនការយល់ដឹងជាធារណៈអំពីបទល្មើសព្រៃឈើ និងវិធានការនានារបស់រាជរដ្ឋាភិបាល, បង្កើតប្រព័ន្ធទទួលសារដែលអាចឱ្យសារណៈជនផ្តល់ពត៌មានពីបទល្មើសព្រៃឈើ។។

PUBLIC REGIONAL CONSULTATION WORKSHOP ON NATIONAL FOREST PROGRAMME
IN SOUTHERN TONLESAB LAKE FA INSPECTORATE
PURSAT, 19-20 MARCH 2009
GROUP DISCUSSION REGISTRATION LIST

**GROUP 1: FOREST DEMARCATION**

| NO. | NAME | ORGANIZATION | SIGNATURE |
|---|---|---|---|
| 1 | MEAS MAKARA | FA | |
| 2 | LANH SITHAORN | COMMUNE CHIEF OF ANSAR CHAMBAK | |
| 3 | MAK SOUN | SARF, PURSAT | |
| 4 | KROCH SOK THON | DEPUTY CHIEF OF ROLEAPHAER DISTRIC | |
| 5 | SORN SOPHEAP | COMMUNITY NEANG KANGREY MOUNTAIN | |
| 6 | LAON SIVY | COMMUNITY KBAL TRACH COMMUNE, PURSAT | |
| 7 | MAM THON | COMMUNE CHIEF OF OSANDAN | |
| 8 | CHHEANG KUY HY | KAMPONGSPEU PROVINCE | |
| 9 | SAR SAT | ACTION FOR ENVIRONMENT AND COMMUNITY, NGO | |
| 10 | NEM PHOEUN | FA | |
| 11 | NOUN SOCHEAT | COMMUNITY, KAMPONGCHHNAING | |
| 12 | MAON EANGLY | CHIEF OF KAMPONG LAENG DISTRICT | |
| 13 | KHHIEV SOPHOEUN | COMMUNE COUNCIL | |
| 14 | CHAB SOKHHOEUN | THNOUT CHUM COMMUNE | |
| 15 | KIM NARA | FA, PURSAT | |
| 16 | NOY SAM OL | FA | |
| 17 | MAN VUTHY | FA | |
| 18 | SIN KOSAL | FA | |
| 19 | KOT BORAN | FA, BATTAMBANG | |
| 20 | CHHAY NARETH | FA, SAM LOUT | |
| 21 | MARK VANNY | FA MOUNG RUSSEY | |
| 22 | TEANG DAVID | FA, BATTAMBANG DIVISION | |
| 23 | PANN PHOUN | SAMLOUT DISTRICT | |
| 24 | BEN BOLINNA | FA, ROMEAS | |
| 25 | OM CHROL | KRAINGSKEA COMMUNE | |
| 26 | OUN YANG | CHIEF OF VEALVENG DISTRICT | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

PUBLIC REGIONAL CONSULTATION WORKSHOP ON NATIONAL FOREST PROGRAMME
IN SOUTHERN TONLESAB LAKE FA INSPECTORATE
PURSAT, 19-20 MARCH 2009
GROUP DISCUSSION REGISTRATION LIST

**GROUP 2. NATIONAL FOREST MANAGEMENT AND CONSERVATION**

| NO. | NAME | ORGANIZATION | SIGNATURE |
|---|---|---|---|
| 1 | KHORN SARETH | FA | |
| 2 | CHHUM SAMNANG | FA | |
| 3 | SAOM SOTHORNIN | PHNOM PENH | |
| 4 | UON SAM OL | FA | |
| 5 | HAM SARAVUTH | FA | |
| 6 | KONG DARITH | FA, PURSAT | |
| 7 | SOK SOVANNA | EPDo | |
| 8 | OR SOPHEAK | MIP FOUNDATION, SAMLOUT DISTRICT | |
| 9 | NOUN SOKHUNTHEA | CHIEF OF SAMLOUT COMMUNE | |
| 10 | TOCH MONY | FA | |
| 11 | SANN KIMKHHEANG | FA, BATTAMBANG | |
| 12 | PROEUNG SOKHHEANG | FA, BATTAMBANG | |
| 13 | PHAY SENGHOUT | DEPARTMENT OF LAND MANAGEMENT | |
| 14 | ITH VANNMONY | MONK FROM HAE PHKA PAGODA | |
| 15 | UNG RITHY | COMMITTEE MEMBER OF HAE PHKA PAGODA | |
| 16 | NAM NY | SAMLOUT DISTRICT, BATTAMBANG | |
| 17 | VANE LIMHEANG | SAMLOUT | |
| 18 | IN OEUN | COMMUNITY CHIEF OF PHNOM POUT, BATTAMBANG | |
| 19 | PICH MALAY | CHIEF OF ROKHAKIRI DISTRICT | |
| 20 | LOM SAOM | CHIEF OF MOUNRUSSEY DISTRICT | |
| 21 | TUY SAM AN | CHIEF OF ROKHAKIRI COMMUNE | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

PUBLIC REGIONAL CONSULTATION WORKSHOP ON NATIONAL FOREST PROGRAMME
IN SOUTHERN TONLESAB LAKE FA INSPECTORATE
PURSAT, 19-20 MARCH 2009
GROUP DISCUSSION REGISTRATION LIST

**GROUP 3: FOREST LAW ENFORCEMENT AND GOVERNANCE**

| NO. | NAME | ORGANIZATION | SIGNATURE |
|---|---|---|---|
| 1 | SENG VISAL | FA, PURSAT | |
| 2 | LONG BOUNG | TECHNICAL ASSISTANCE | |
| 3 | SOUN SOVANN | FA | |
| 4 | SAO DAROEUN | CHIEF OF BAKAN DISTRICT | |
| 5 | CHEA SARAN | FA | |
| 6 | KANE PHAN | FA | |
| 7 | CHHEANG THINA | FA | |
| 8 | UM SOPHA | FA, PURSAT | |
| 9 | PO BUNLENG | FA, KANDAL CANETONMENT | |
| 10 | TOUCH SAMBO | CHIEF OF PHNOM KRAVANH | |
| 11 | NAO THOEUN | RAKSMEY KAMCHUCHEA NEWS PAPERS | |
| 12 | SUM LEUM | DEPARTMENT OF INFROMATION | |
| 13 | BAN SOPHAL | DARASY COMPANY | |
| 14 | SO SEN | MEMBER OF COMMUNE COUNCIL | |
| 15 | KIM NHAN | COMMUNITY MEMBER | |
| 16 | CHEA HOUT | FA, KRAVANH | |
| 17 | LIV SAROM | COMMUNITY OFRESTRY, KAMPONGSPEU PROVINCE | |
| 18 | HOR SAM ATH | COMMUNITY BATTAMBANG | |
| 19 | KIM SENG | COMMUNITY BATTAMBANG | |
| 20 | LIM BUN CHHORN | CHIEF OF FA TRIAGE TOM | |
| 21 | CHEA BUNLY | FA, PURSAT | |
| 22 | TEP CHANTY | FA, PURSAT | |
| 23 | CHANN SOCHEAT | DEPUTY CHIEF OF LEGISLATIVE DIVISION, MJP | |
| 24 | LY PHEAK | COMMUNITY, KRAKOR, PURSAT | |
| 25 | OEUN SARIM | COMMUNITY, BATTAMBANG | |
| 26 | CHEP PON | COMMUNITY TRAPAING PHKORM, KG. CHHNAING | |
| 27 | SAOM SALOUT | COMMUNITY, BATTAMBANG | |
| 33 | CHANN SOTHA | FA, BOVEL DIVISION, BATTAMBANG | |
| 34 | | | |

PUBLIC REGIONAL CONSULTATION WORKSHOP ON NATIONAL FOREST PROGRAMME
IN SOUTHERN TONLESAB LAKE FA INSPECTORATE
PURSAT, 19-20 MARCH 2009
GROUP DISCUSSION REGISTRATION LIST

**GROUP 4: COMMUNITY FORESTRY**

| NO. | NAME | ORGANIZATION | SIGNATURE |
|---|---|---|---|
| 1 | OU KIMTHY | COMMUNITY FROM KAMPONGLENG DISTRICT | |
| 2 | SOK CHAMROEUN | COOMUNITY ANSARCHAMBAK, KRAKOR | |
| 3 | PHIN DARA | VTH | |
| 4 | SOUNG VAN | COOMNITY DAMREI CHARKPHLUK, PHNOM SROUCH | |
| 5 | KHHENG SOLAN | FA PURSAT CANETONMENT | |
| 6 | KUCH VENG | COMMUNITY, PURSAT | |
| 7 | SEANG SITHA | COOMUNITY, SA-ORNG VILLAGE, PRASNIT COMMUNE | |
| 8 | NHIP THY | LWF, ORAL DISTRICT | |
| 9 | CHEM SARIM | ORAL DISTRICT | |
| 10 | YOU SOKPHEARAK | CHIEF OF SAMNOM COMMUNE, ORAL DISTRICT | |
| 11 | PEN SOKHHON | KNCED, NGO | |
| 12 | NUTH MARCHHONG | KNT, NGO | |
| 13 | HOUT LANGDY | UNKIDEN, NGO | |
| 14 | KANG SOVANN | PONLEU KUMAR, NGO | |
| 15 | PROM VIBOLROTANAK | VEASNA KHMER, NGO | |
| 16 | SOUN KINSAN | KCDA, NGO | |
| 17 | CHANN PHANNA | COMMUNITY | |
| 18 | LEUNG PHIN | COMMUNITY | |
| 19 | DAOK SOK | COMMUNITY, BANGKOK LUNGVEAK | |
| 20 | LONG THIM | COMMUNITY | |
| 21 | CHHOM HAN | CHIEF OF UANLUNGVIL COMMUNE | |
| 22 | NGOUN LINA | COMMUNITY, KAMPONGPOR | |
| 23 | VANN SOKHIM | MONK FROM CF KAMPONGPOR, KAMPONGCHHNAING | |
| 24 | VOR KHAM | CHIEF OF KRAINGDEIVAY COMMUNE | |
| 25 | MIK RATH | COMMUNITY CHIEF | |
| 26 | PHATH SOPHAON | COMMUNITY CHIEF | |
| 27 | LEANG KIMTHON | COMMUNITY CHIEF OF ROLEAB | |
| 28 | ROS SAMNANG | COMMUNITY CHIEF OF DANGKOT | |
| 29 | SAY SOCHEATH | COMMUNITY CHIEF OF BOEUNG SLEK | |
| 30 | KHHEANG SOCHIVY | OXFAM GB | |
| 31 | KIM MAO | COMMUNITY CHIEF OF PHNOM SRANG | |
| 32 | CHEY BUN NHOEUN | COMMUNITY CHIEF OF BOEUNGCHHOUK | |
| 33 | PUTH CHHAY | COMMUNITY CHIEF, ORAL | |
| 34 | PHO PHAN | COMMUNITY CHIEF OF TAOPHON | |
| 35 | SAN CHHEABLY | DEPUTY CHIEF OF OBAKOR COMMUNITY | |
| 36 | CHEA BUNTHA | FA | |

PUBLIC REGIONAL CONSULTATION WORKSHOP ON NATIONAL FOREST PROGRAMME
IN SOUTHERN TONLESAB LAKE FA INSPECTORATE
PURSAT, 19-20 MARCH 2009
GROUP DISCUSSION REGISTRATION LIST

**GROUP 5: CAPACITY BUILDING AND RESEARCH DEVELOPMENT**

| NO. | NAME | ORGANIZATION | SIGNATURE |
|---|---|---|---|
| 1 | HEM CHANRITHY | FA | |
| 2 | CHAY CHEDTHA | FA | |
| 3 | CAHNN SOPHAL | FA | |
| 4 | VANN SOKHIM | COMMUNITY, POR COMMUNE | |
| 5 | NUP SOTHEA | FA | |
| 6 | YIN PICH | COMMUNITY | |
| 7 | CHHUN OUN | AARR | |
| 8 | NOUL SOPHAL | PVT | |
| 9 | CHEA PHAON | COMMUNITY, KRAINGSKEAR ,KAMPONGCHHNAING | |
| 10 | CHHANG PHURIN | FA, PAILIN | |
| 11 | SAMRITH VANNA | FA | |
| 12 | VEY SAMNANG | FA, BORSETH DIVISION | |
| 13 | KIM CHANTHA | FA, PURSAT CANETONMENT | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

PUBLIC REGIONAL CONSULTATION WORKSHOP ON NATIONAL FOREST PROGRAMME
IN SOUTHERN TONLESAB LAKE FA INSPECTORATE
PURSAT, 19-20 MARCH 2009
GROUP DISCUSSION REGISTRATION LIST

**GROUP 6: NATIONAL FOREST PROGRAM FRAMEWORK DOCUMENTS**

| NO. | NAME | ORGANIZATION | SIGNATURE |
|---|---|---|---|
| 1 | SOKH HENG | NFP COORDINATOR | |
| 2 | MA SOKHTHA | FA | |
| 3 | KANG KOEUN | COMMUNITY | |
| 4 | YIN NOU | COMMUNITY | |
| 5 | MAO CHANDARA | FA, PURSAT CANETONMENT | |
| 6 | IM SOPHY | FA, PURSAT CANETONMENT | |
| 7 | PIN PHANNY | FA, SOUTHERN TONLESAB LAKE FA INSPECTORATE | |
| 8 | ROS BUNTHA | PSDD/UNDP | |
| 9 | SOEUN VANNA | KAMPONGCHHNAING | |
| 10 | IN CHANMOR | PURSAT | |
| 11 | CHAB SEATH | FA, DEPUTY VEALVENG DIVISION | |
| 12 | CHAN SOTHA | CHIEF, FA BOVEL DIVISION | |
| 13 | PEAK MANAU | RECOFTC COORDINATOR, PURSAT | |
| 14 | CHABKHHEUN | COMMUNITY | |
| 15 | TIM SAVORN | KARAKOR DISTRICT, PURSAT | |
| 16 | VEN SOKORB | SUB. PURSAT | |
| 17 | PREAB CHREANG | DEPARTMENT OF INDUSTRY, PURSAT | |
| 18 | PIN CHANNARITH | DEPARTMENT OF RURAL DEVELOPMENT | |
| 19 | SAN CHHEABLY | COMMUNITY, OBAKTRA | |
| 20 | SOK MY | KAMPONGCHHNAING | |
| 21 | ROS NOEUN | PAILIN | |
| 22 | CHEA BUNTHA | FA, DEPUTY CHIEF CHHNAING CANETONMENT | |
| 23 | HEANG HEANG | COMMUNITY CHIEF | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ  សាសនា  ព្រះមហាក្សត្រ
## របាយការណ៍ពីលទ្ធផលនៃសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈស្តីពីកម្មវិធីព្រៃឈើជាតិ
## នៅរដ្ឋបាលព្រៃឈើខាងត្បូងបឹងទន្លេសាប

ខេត្ត ពោធិ៍សាត់, ថ្ងៃទី ១៩-២០ ខែ មីនា ឆ្នាំ ២០០៩

### ១_សេចក្តីផ្តើម

រដ្ឋបាលព្រៃឈើ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ រួមជាមួយបណ្តាភាគីពាក់ព័ន្ធបានរួមគ្នារៀបចំសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិដែលជាជំហានសំខាន់មួយឆ្ពោះទៅរកការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។ កម្មវិធីនេះមានកម្មវត្ថុឆ្លើយតបតំរូវការជាលក្ខណៈមូលដ្ឋាន ថ្នាក់ជាតិ និង សាកល ដោយផ្តល់ឯកសារមានតម្លាភាព និង មានចំណងទាក់ទងគ្នាជាយុទ្ធសាស្ត្រមួយដើម្បីធ្វើផែនការ គ្រប់គ្រង ប្រើប្រាស់ ការពារ និង បង្កើនធនធានព្រៃឈើ បំពេញសេចក្តីត្រូវការដល់មនុស្សជំនាន់បច្ចុប្បន្ន និង ជំនាន់ក្រោយៗទៀត។

ក្រុមការងារមួយដែលមានតំណាងពីរដ្ឋបាលព្រៃឈើ ក្រសួងពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល វិស័យឯកជនបានរួមគ្នារៀបចំសេចក្តីព្រាងកម្មវិធីព្រៃឈើដើម្បីគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ កម្មវិធីព្រៃឈើជាតិជាឯកសារគោលមួយដែលក្នុងនោះមានកម្មវិធីចំនួន ៦ ដូចខាងក្រោម :

- កម្មវិធីកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និង ការចុះបញ្ជិកា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- កម្មវិធីគ្រប់គ្រងធនធានព្រៃឈើជាតិ និង ការអភិរក្ស
- កម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ច
- កម្មវិធីសហគមន៍ព្រៃឈើជាតិ
- កម្មវិធីអភិវឌ្ឍសមត្ថភាព និង ការស្រាវជ្រាវ
- កម្មវិធីហិរញ្ញប្បទានដើម្បីការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព

### ២_គោលបំណងនៃសិក្ខាសាលា

សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈអំពីកម្មវិធីព្រៃឈើជាតិ ត្រូវបានរៀបចំដោយអធិការដ្ឋានរដ្ឋបាលព្រៃឈើ និងមានឧបត្ថម្ភផ្នែកថវិកាពីដៃគូអភិវឌ្ឍន៍មានដានីដា និង FAO។ គោលបំណងនៃសិក្ខាសាលាគឺ កែលំអឯកសារព្រាងកម្មវិធីព្រៃឈើជាតិឱ្យកាន់តែល្អប្រសើរ បង្កើនការផ្សព្វផ្សាយ និង ការយល់ដឹងអំពីកម្មវិធីព្រៃឈើជាតិ ប្រមូលមតិ, ទស្សនៈ និង យោបល់ ពីអ្នកពាក់ព័ន្ធនានានៅថ្នាក់មូលដ្ឋាន បង្កើនការគាំទ្រ និងការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍ និងការអនុវត្តកម្មវិធីព្រៃឈើជាតិ។

## ៣. ទីកន្លែង និង ពេលវេលា

សិក្ខាសាលពិគ្រោះជាសាធារណៈសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈអំពីកម្មវិធីព្រៃឈើជាតិដែលធ្វើនៅអធិការដ្ឋានរដ្ឋបាលព្រៃឈើខាងត្បូងបឹងទន្លេសាបត្រូវបានរៀបចំនៅខេត្តពោធិ៍សាត់ក្នុងមជ្ឈមណ្ឌលអភិវឌ្ឍន៍ **ប៊ុន រ៉ានី ហ៊ុន សែន** នៅថ្ងៃទី ១៩-២០ ខែ មីនា ឆ្នាំ ២០០៩។

## ៤.អ្នកចូលរួម

សិក្ខាសាលាពិគ្រោះយោបល់នេះត្រូវបានរៀបចំឡើងក្រោមអធិបតីភាពឯកឧត្តម **ជា សំអាង** អនុប្រធានរដ្ឋបាលព្រៃឈើ និង សមាជិកគណៈអធិបតីជាអភិបាលរងមកពីខេត្ត កំពង់ស្ពឺ កំពង់ឆ្នាំង កណ្ដាល ពោធិ៍សាត់ និង បាត់ដំបង ព្រមទាំងសមាជិកមកពីអង្គភាពពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន សហគមន៍មូលដ្ឋាន សរុបទាំងអស់ ចំនួន ១៥៨ នាក់។

- o រដ្ឋបាលព្រៃឈើមូលដ្ឋាន ៤៤ នាក់
- o អាជ្ញាធរមូលដ្ឋាន ៣០ នាក់
- o សហគមន៍មូលដ្ឋាន ៣៥ នាក់
- o អង្គការក្រៅរដ្ឋាភិបាលនៅមូលដ្ឋាន វិស័យឯកជន អ្នកសារព័ត៌មាន និង ទូរទស្សន៍ ៣១ នាក់
- o មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធជុំវិញខេត្ត ១០ នាក់
- o អ្នករៀបចំសិក្ខាសាលា ( ក្រុមពិគ្រោះយោបល់ ក្រុមជំនួយការ... ) ១០ នាក់

## ៤.១. ចំណាប់អារម្មណ៍ពីគណៈអធិបតីក្នុងពិធីបើកសិក្ខាសាលា

ក្នុងសន្ទរកថាបើកសិក្ខាសាលា ឯកឧត្តម **ឌី គីមតុក** អភិបាលរងខេត្តពោធិ៍សាត់ បានបញ្ជាក់ថា ខេត្តពោធិ៍សាត់ មានផ្ទៃដីទំហំ ១.១៥៨.៩៩១ ហិកតា ក្នុងនោះមានព្រៃឈើចំនួន ៨៨៥.៤៤០ ហិកតា ដែលស្មើនឹង ៧៦,៨២ ភាគរយ និងមានប្រជាពលរដ្ឋចំនួន ៤២៦.៧៥៨នាក់ ស្មើនឹង ៨៣.១៥៣គ្រួសារ ដែលភាគច្រើនជាកសិកររស់នៅពឹងផ្អែកស្ទើរតែទាំងស្រុងលើធនធានព្រៃឈើ និងធនធានជលផល។ ដូច្នេះការបាត់ធនធានព្រៃឈើ និងព្រៃលិចទឹកបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋយើង ក៏ដូចប្រជាជនក្នុងតំបន់ផងដែរ ដូចនេះមតិ យោបល់ ទស្សនៈ អនុសាសន៍ ក្នុងសិក្ខាសាលាពិគ្រោះយោបល់នេះ នឹងចូលរួមចំណែកកែលំអកម្មវិធីព្រៃឈើជាតិ ការអភិរក្សការគ្រប់គ្រងធនធានព្រៃឈើនៅកម្ពុជាដើម្បីបំរើសេចក្តីត្រូវការនៅថ្នាក់មូលដ្ឋាន ក៏ដូចជាគាំទ្រដល់គោលដៅអភិវឌ្ឍន៍សហសវត្សរបស់រាជរដ្ឋាភិបាលកម្ពុជាដែលប្តេជ្ញាថែរក្សាគំរបព្រៃឈើឱ្យបាន ៦០ ភាគរយធៀបនឹងផ្ទៃដីប្រទេស នៅឆ្នាំ ២០១៥។

ក្នុងឱកាសបើកសិក្ខាសាលានេះដែរ ឯកឧត្តម **ជា សំអាង** អនុប្រធានរដ្ឋបាលព្រៃឈើបានថ្លែងថា តាំងពីអាណត្តិទី ២ នៃរាជរដ្ឋាភិបាលកម្ពុជាបានដាក់វិស័យ ៤ ជាអាទិភាពក្នុងយុទ្ធសាស្ត្រ ត្រីកោណ និង ចតុកោណរបស់ខ្លួនគឺការអភិរក្សធានធានព្រៃឈើ ការអភិបាលកិច្ចល្អ ការអភិវឌ្ឍន៍សង្គម និង ការកាត់បន្ថយភាពក្រីក្រ។ ក្នុងវិស័យព្រៃឈើយើងបានរៀបចំលិខិតបទដ្ឋានចំនួន ២៩ ដែលក្នុងនោះមានច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យ ប្រកាស។ល។ ព្រមទាំងបាន និងកំពុងរៀបចំមួយចំនួនទៀតក្នុងគោលបំណងគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព។ ខេត្ត ពោធិ៍សាត់ស្ថិតជាប់ជួរភ្នំក្រវាញដែលយើងបានដាក់តំបន់នេះជាតំបន់អភិរក្ស ឯកឧត្តមក៏បានបន្ថែមទៀតថា យើងបានទទួលមរតកធនធានព្រៃឈើពីបុព្វបុរសរបស់យើង ហើយយើងក៏ជាស្ពានចម្លងមរតកទាំងនេះទៅកូនចៅជំនាន់ក្រោយៗទៀត ពួកគេទាំងអស់មិនអាចរស់នៅដោយគ្មានព្រៃឈើបានទេ។ ឯកឧត្តមក៏បង្ហាញក្តីព្រួយបារម្ភណ៍ដែលនៅលើពិភពលោកសព្វថ្ងៃ កំណើនធនធានព្រៃឈើមិនសមាមាត្រនឹងកំណើនមនុស្ស ហើយលទ្ធភាពផ្តល់ផលនៃព្រៃឈើ មិនសមាមាត្រនឹងសេចក្តីត្រូវការរបស់មុនស្សលោកដូច្នេះកម្មវិធីព្រៃឈើជាតិជាសេចក្តីត្រូវការជាប្រវត្តិសាស្ត្ររបស់កម្ពុជា ហើយមតិ យោបល់ ទស្សនៈ អនុសាសន៍ក្នុងសិក្ខាសាលា នឹងរួមចំណែកកែលំអកម្មវិធីព្រៃឈើជាតិឱ្យល្អប្រសើរដើម្បីបំពេញតំរូវការនៅថ្នាក់មូលដ្ឋាន។

## ៥. វិធីសាស្ត្រនៃសិក្ខាសាលា

សិក្ខាសាលាតាមបណ្តាអធិការដ្ឋានរដ្ឋបាលព្រៃឈើនីមួយៗ មានអ្នកជំនួយការ ៤ នាក់ ធ្វើការសហការជាមួយអ្នកចងក្រងកម្មវិធីទាំង ៦ អ្នករៀបចំសិក្ខាសាលា ព្រមទាំងមានការសំរបសំរួលណែនាំពីអ្នកសំរបសំរួលកម្មវិធីព្រៃឈើជាតិលោក បណ្ឌិត **សុខ ហេង** ដើម្បីឱ្យដំណើរការនៃសិក្ខាសាលាប្រព្រឹត្តិបានរលូនល្អ។ អ្នកជំនួយការទាំង ៤ នាក់ ម្នាក់ៗទទួលដឹកនាំសំរបសំរួល រៀបចំសំភារៈសំរាប់ដំណើរការសិក្ខាសាលា និង សរសេររបាយការណ៍លទ្ធផលនៃសិក្ខាសាលាសំរាប់មួយអធិការដ្ឋានរដ្ឋបាលព្រៃឈើ។

សិក្ខាសាលារយៈពេលពីរថ្ងៃ ត្រូវបានរៀបចំដោយថ្ងៃទី ១ សំរាប់ការធ្វើបទបង្ហាញពីអ្នកចងក្រងកម្មវិធីទាំង ៦ និង អនុកម្មវិធីមួយចំនួនទៀត ហើយបន្ទាប់ពីបទបង្ហាញនៃកម្មវិធីនីមួយៗមានសំណួរ-ចម្លើយពិភាក្សាតាមកម្មវិធី និងចុងបញ្ចប់នៃកម្មវិធីថ្ងៃទី ១ មានវេទិការសំរាប់ការសួរ-ឆ្លើយរយៈពេល ១ ម៉ោង និង ៣0នាទីបន្ថែមទៀតទៅកម្មវិធីទាំង៦។

ថ្ងៃទី ២ នៃពិធីសិក្ខាសាលា គឺសំរាប់ការបែងចែកក្រុមពិភាក្សាតាមកម្មវិធីទាំង ៦ ដោយសិក្ខាកាមទាំងអស់បានចុះឈ្មោះពិភាក្សា តាមចំណង់ចំណូលចិត្ត បទពិសោធន៍ និងការងារចំពោះរបស់ខ្លួន ហើយបន្ទាប់ពីការពិភាក្សារួចតំណាងក្រុមនីមួយៗដែលសុទ្ធតែមកពីសហគមន៍មូលដ្ឋានបានធ្វើបទបង្ហាញពីលទ្ធផលរបស់ក្រុមខ្លួនព្រមទាំងបានឆ្លើយសំណួរដែលបានលើកឡើងយ៉ាងក្បោះក្បាយ។

## ៦. លទ្ធផលនៃសិក្ខាសាលា

ដំណើរការនៃសិក្ខាសាលាប្រព្រឹត្តិទៅមានភាពរលូន ដោយមានសិក្ខាកាមសរុបចំនួន ១៥២ នាក់បានចុះឈ្មោះតាមក្រុម ឬកម្មវិធីពិភាក្សានីមួយៗ ដោយក្រុមទី១ ពិភាក្សាកម្មវិធីទី ១ មានសមាជិកចូលរួមចំនួន ២៦ នាក់ ក្រុមទី ២

ចំនួន ២១ នាក់ ក្រុមទី ៣ មានសមាជិកចូលរួមចំនួន ៣៣ នាក់ ក្រុមទី ៤ មាន ៣៦ នាក់ ក្រុមទី ៥ មាន ១៣ នាក់ និង ក្រុមទី ៦ មានសមាជិកចំនួន ២៣ នាក់ ពិភាក្សាលើប្រធានបទ **"ឯកសារគ្រោងនៃកម្មវិធីព្រៃឈើជាតិ"** ។

ក្រោយពេលពិភាក្សាបានលទ្ធផលរួចហើយក្រុមនីមួយៗបានឡើងធ្វើបទបង្ហាញ និង ឆ្លើយសំណួរទាក់ទងនឹងកម្មវិធីរបស់ខ្លួនដោយមានសមាជិកក្រុម និង អ្នកចងក្រងកម្មវិធីជួយសំរបសំរួលយ៉ាងអស់ពីលទ្ធភាព ធ្វើឱ្យបរិយាកាសនៃសិក្ខាសាលាមានសភាពផុសផុលយ៉ាងខ្លាំង ។

សេចក្ដីសង្ខេបលទ្ធផលក្រុមពិភាក្សានីមួយៗមានដូចខាងក្រោម :

### ៦.១- ក្រុម១ : កម្មវិធីកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និង ការចុះបញ្ជិកា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

មានសមាជិកចំនួន ២៦ នាក់ តំណាងដោយលោកស្រី **ឡោន ស៊ីវ៉ី** មកពីសហគមន៍ព្រៃឈើ ក្បាលត្រាច ខេត្តពោធិ៍សាត់ ឡើងធ្វើបទបង្ហាញ ដែលបានពិភាក្សាលើប្រធានបទ :

១. តើអ្នកយល់ដូចម្ដេចចំពោះកម្មវិធី ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និង ការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍? គួរមានអនុកម្មវិធីអ្វីបន្ថែមទៀត?
២. បញ្ហាប្រឈម និងដំណោះស្រាយ ក្នុងការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍
៣. តើត្រូវធ្វើដូចម្ដេចដើម្បីបង្កើនការកំណត់ព្រំព្រទល់សម្បត្តិព្រៃឈើចិន្ត្រៃយ៍សម្រេចបានឆាប់រហ័ស?
៤. តើអជ្ញាធរ សហគមន៍ និង ប្រជាជនមូលដ្ឋានចូលរួមដូចម្ដេចក្នុងការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍?
៥. តើត្រូវមានស្ថាប័នពាក់ព័ន្ធអ្វីខ្លះចូលរួមក្នុងការចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍?
៦. បន្ទាប់ពីបានកំណត់ព្រំប្រទល់រួចតើអាជ្ញាធរដែនដី និង សហគមន៍ ប្រជាពលរដ្ឋមូលដ្ឋានចូលរួមដូចម្ដេចក្នុងការថែរក្សា?

### ៦.២- ក្រុម ២ : កម្មវិធីគ្រប់គ្រងធនធានព្រៃឈើជាតិ និង ការអភិរក្ស

មានសមាជិកចូលរួមចំនួន ២១ នាក់ និង តំណាងដោយលោក **ឡាំ សោម** ជាអភិបាលស្រុក មោងឫស្សី ឡើងធ្វើបង្ហាញ និង បានពិភាក្សាលើអនុកម្មវិធីចំនួន ០៨ ដូចខាងក្រោម :

អនុកម្មវិធីទី១ : ការរៀបចំផែនការគ្រប់គ្រងព្រៃឈើជាតិ

អនុកម្មវិធីទី២ : សារពើភ័ណ្ឌព្រៃឈើជាតិ

២.១ : សារពើភ័ណ្ឌព្រៃឈើជាតិ

២.២ : ទម្រង់តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្ដីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

អនុកម្មវិធីទី ៣ : ការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងព្រៃបម្រុងទុកអចិន្ត្រៃយ៍ក្រៅពីព្រៃសហគមន៍

អនុកម្មវិធីទី ៤ : ការអភិរក្សធនធានសេនេទិច និងបង្កើតប្រភពគ្រាប់ពូជសម្រាប់កម្មវិធីដាំឈើ

អនុកម្មវិធីទី ៥ : អភិវឌ្ឍពហុចំការដាំឈើ

អនុកម្មវិធីទី ៦ : ការរៀបចំប្រព័ន្ធគ្រប់គ្រងព្រៃការពារ រួមមានការអភិរក្សធនធានជីវៈចំរុះ និងការអភិវឌ្ឍន៍ទេសចរណ៍

អនុកម្មវិធីទី ៧ : ការកែច្នៃផលិតផលឈើ និងទីផ្សារ

អនុកម្មវិធីទី ៨ : ការអភិវឌ្ឍន៍បច្ចេកវិជ្ជាឈើ និងការកែច្នៃ

## ៦.៣- ក្រុម ៣ :កម្មវិធីពង្រឹងការអនុវត្តច្បាប់ ស្តីពីព្រៃឈើនិងអភិបាលកិច្ច

ក្រុមនេះមានសមាជិកចំនួន ៣៣ នាក់ មានលោក **ហោ សំអាត** មកពីសហគមន៍នេសាទ ខេត្ត បាត់ដំបងឡើងធ្វើបទបង្ហាញ ដែលបានធ្វើការពិភាក្សាលើចំណុចសំខាន់ៗដូចខាងក្រោម :

១- តើមូលហេតុចំបងអ្វីខ្លះដែលនាំឱ្យធនធានព្រៃឈើថយចុះ?

២- តើនរណាខ្លះដែលទទួលផលប្រយោជន៍ពីធនធានព្រៃឈើ?

៣- តើភាគីពាក់ព័ន្ធណាខ្លះដែលគួរចូលរួមក្នុងការពង្រឹងការអនុវត្តច្បាប់ និងអភិបាលកិច្ច ហើយមានតួនាទីអ្វីខ្លះ?

៤- តើអភិបាលកិច្ចល្អក្នុងវិស័យព្រៃឈើមានអ្វីខ្លះ?

៥- តើមធ្យោបាយផ្សព្វផ្សាយណាខ្លះដើម្បីបង្កើនការយល់ដឹងជាសាធារណៈអំពីច្បាប់ស្តីពីព្រៃឈើ និង លិខិតបទដ្ឋាននានាឱ្យមានប្រសិទ្ធភាពខ្ពស់?

៦- តើការផ្តល់ពត៌មានបទល្មើសព្រៃឈើគួរធ្វើតាមវិធីណាខ្លះ?

៧- តើត្រូវមានវិធានការយ៉ាងណាដើម្បីទប់ស្កាត់ និងដោះស្រាយ ចំពោះបុគ្គលដែលបានតាំងទីលំនៅ និង យកដីព្រៃឈើរបស់រដ្ឋ?

## ៦.៤-ក្រុម ៤ : សហគមន៍ព្រៃឈើ

សមាជិកចូលរួមក្នុងក្រុមនេះមានចំនួន ៣៦ នាក់ និង មានព្រះតេជគុណព្រះនាម វ៉ាន់ សុឃឹម តំណាងមកពីសហគមន៍ព្រៃឈើ ឃុំ ពោធិ៍ ខេត្ត កំពង់ឆ្នាំង ធ្វើបទបង្ហាញលទ្ធផលដែលក្រុមបានពិភាក្សាលើប្រធានបទ :

១- តើលោក លោកស្រីមានបទពិសោធន៍អ្វីខ្លះ ពីការចូលរួមគ្រប់គ្រងធនធានព្រៃឈើនៅក្នុងមូលដ្ឋានរបស់ខ្លួន?

២- តើការចូលរួមគ្រប់គ្រងធនធានព្រៃឈើកន្លងមករបស់លោក លោកស្រីបានជួបលំបាក យ៉ាងណាខ្លះ?

៣- តើគួរមានអនុកម្មវិធីអ្វីបន្ថែមទៀតដើម្បីធានាថាបម្រើឱ្យការងារសហគមន៍ព្រៃឈើនៅមូលដ្ឋានរបស់យើង?

៤- តើគួរមានសកម្មភាពសំខាន់ៗអ្វីខ្លះទៀត នៅក្នុងអនុកម្មវិធីនីមួយៗ ?

**សកម្មភាពនៅក្នុងអនុកម្មវិធីទី ១ រួមមាន**

- សហគមន៍ និងការកែលំអរតំបន់ទេសចរណ៍
- ពិធីបំបួសដើមឈើ
- ការទប់ស្កាត់ និងកាត់បន្ថយមហន្តរាយដែលកើតឡើងរាល់ឆ្នាំ ( ភ្លើងព្រៃ)

**សកម្មភាពនៅក្នុងអនុកម្មវិធីទី ២ រួមមាន**

- o បង្កើតថ្នាលបណ្តុះកូនឈើនៅក្នុងសហគមន៍
- o លើកទឹកចិត្តជាប្រាក់ឧបត្ថម្ភ សហគមន៍ព្រៃឈើក្នុងការគ្រប់គ្រងព្រៃ សហគមន៍

**សកម្មភាពនៅក្នុងអនុកម្មវិធីទី ៣ រួមមាន**

- o បង្កើតបណ្តាញឱ្យមានគ្រប់ស្ថាប័ន
- o បង្កើតសហព័ន្ធសហគមន៍ព្រៃឈើថ្នាក់តំបន់
- o រៀបចំប្រជុំប្រចាំត្រីមាស
- o រៀបចំបណ្តាញសហគមន៍ព្រៃឈើជាសម្ព័ន្ធថ្នាក់ខេត្ត ថ្នាក់តំបន់ និងថ្នាក់ជាតិ
- o ចុះត្រួតពិនិត្យជាប្រចាំ
- o ផាកពិន័យ ឬចាប់ឃាត់-ប្រមូលឯកសារ និងពតិមានសំខាន់ៗនៅក្នុងសហគមន៍
- o បង្កើតប៉ុស្តិ៍យាមក្នុងព្រៃសហគមន៍
- o បង្កើតក្រុមការពារព្រៃសហគមន៍

**សំណូមពរ :** សុំដកជំហ៊ានទី ០៩នៅក្នុងអនុកម្មវិធីទី១ មកដាក់ក្នុងអនុកម្មវិធីទី ២វិញ ។

៥-ក្នុងរយះពេល ៥ ឆ្នាំដំបូងតើយើងគួរអនុវត្តសកម្មភាពសំខាន់ៗអ្វីខ្លះ? ហើយរំពឹងថានឹងទទួលបានលទ្ធផលដូចម្តេច?

៦-តើគួរពង្រឹងកិច្ចសហការបែបណារវាងរដ្ឋបាលព្រៃឈើ សហគមន៍ អាជ្ញាធរ មូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងទៀត?

៧-តើត្រូវការអភិវឌ្ឍន៍ព្រៃសហគមន៍យ៉ាងដូចម្តេច ដើម្បីធានាឱ្យមានការផ្តល់ផល- អនុផលព្រៃឈើសម្រាប់បម្រើឱ្យសេចក្តីត្រូវការ និង កាត់បន្ថយភាពក្រីក្រ?

៨-ដើម្បីគាំទ្រដល់ការអនុវត្តន៍សហគមន៍ព្រៃឈើឱ្យមានប្រសិទ្ធិភាព តើលោក លោកស្រីត្រូវការចំណេះដឹង និងជំនាញថ្មីៗអ្វីខ្លះ?

## ៦.៥-ក្រុម ៥ : ការអភិវឌ្ឍន៍សមត្ថភាព និងការស្រាវជ្រាវ

ក្រុមមានសមាជិកចំនួន ១២ នាក់ តំណាងដោយ លោក ជា ភ័ណ្ឌ មកពីសហគមន៍ក្រាំងស្គារ ខេត្ត កំពង់ឆ្នាំង ឡើងធ្វើបទបង្ហាញលទ្ធផលដែលក្រុមបានពិភាក្សាលើប្រធានបទ :

១- ពីទស្សនៈរបស់យើង តើគួរមានការគាំទ្របែបណាខ្លះ ដើម្បីជួយដល់សកម្មភាពគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន?

២- តើត្រូវធ្វើដូចម្តេចដើម្បីឱ្យការបណ្តុះបណ្តាលមានប្រយោជន៍សំរាប់មូលដ្ឋាន?

៣- តើកម្មវិធីផ្សព្វផ្សាយអ្វីខ្លះដែលសំខាន់សំរាប់មូលដ្ឋាន?

៤- តើវិធីសាស្ត្រផ្សព្វផ្សាយបែបណាខ្លះដែលមានប្រសិទ្ធភាពដល់មូលដ្ឋាន?

៥- តើត្រូវមានការស្រាវជ្រាវវិស័យព្រៃឈើអ្វីខ្លះដែលសំខាន់សំរាប់មូលដ្ឋាន?

៦- តើគួររៀបចំប្រព័ន្ធវិញ្ញាបនប័ត្រព្រៃឈើបែបណាដែលមានប្រយោជន៏សំរាប់មូលដ្ឋាន?

### ៦.៦-ក្រុម ៦ : ឯកសារគ្រោងនៃកម្មវិធីព្រៃឈើជាតិ

អ្នកចូលរួមពិភាក្សាមានចំនួន ២៣ នាក់ តំណាងឡើងធ្វើបទបង្ហាញគឺ លោកស្រី **កង គឿន** មកពីសហគមន៏ ហើយក្រុមបានពិភាក្សាលើប្រធានបទ :

១- មាតិការឿងនៃឯកសារគោលការណ៍កម្មវិធីព្រៃឈើជាតិ តើមានចំណុចខ្វះខាតអ្វីខ្លះ?

- **បន្ថែមគោលដៅក្នុងសេចក្តីផ្តើម**

២- ក្នុងកម្មវិធីព្រៃឈើជាតិមានកម្មវិធីហៅថា ប្រព័ន្ធពតិមានដើម្បីជួយគាំទ្រដល់ការត្រួតពិនិត្យ និង វាយតំលៃការអនុវត្តឱ្យមានប្រសិទ្ធភាព

២.១. តើភាគីពាក់ព័ន្ធនៅមូលដ្ឋានអាចចូលរួមតាមដាន និង វាយតំលៃការអនុវត្តកម្មវិធីព្រៃឈើជាតិបានយ៉ាងដូចម្តេច?

២.២. តើអ្វីខ្លះដែលអាចយកមកធ្វើជា សូចនាករ សំរាប់តាមដានវាយ តំលៃការអនុវត្តកម្មវិធីព្រៃឈើជាតិ?

៣- តំបន់ព្រៃសម្បទានដែលបានផ្អាក គួរត្រូវគ្រប់គ្រងយ៉ាងណា?

៤- តើកម្មវិធីព្រៃឈើជាតិ អាចជួយដោះស្រាយទំនាស់ដែលអាចកើត ចេញពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចយ៉ាងណាខ្លះ? (ការងារអ្វីខ្លះដែលត្រូវ/គួរធ្វើក្នុងការអនុវត្តកម្មវិធីព្រៃឈើជាតិ)

  - o មុនផ្តល់ដីសម្បទានសេដ្ឋកិច្ច
  - o ក្រោយផ្តល់ដីសម្បទានសេដ្ឋកិច្ច

## ៧. សំណួរ-ចម្លើយ និង សេចក្តីថ្លែងការណ៍របស់សហគមន៍មូលដ្ឋាន

ក្នុងរយៈពេលពីរថ្ងៃនៃសិក្ខាសាលាពិគ្រោះជាសាធារណៈស្តីពីកម្មវិធីព្រៃឈើជាតិ មានសំណួរ និង មតិយោបល់ជាច្រើនត្រូវលើកឡើងដោយអ្នកចូលរួម ជាពិសេសសិក្ខាកាមមកពីសហគមន៏មូលដ្ឋាន ហើយសំណួរទាំងអស់នោះត្រូវបានបកស្រាយបំភ្លឺដោយអ្នកចងក្រងកម្មវិធី និង តំណាងក្រុមពិភាក្សាយ៉ាងក្បោះក្បាយ ហើយសេចក្តីនៃសំណួរចម្លើយ មានភ្ជាប់ក្នុងតារាងឧបសម្ព័ន្ធ។

បន្ថែមពីលើសំណួរ-ចម្លើយក្នុងពេលសិក្ខាសាលា តំណាងសហគមន៏មូលដ្ឋានទាំងអស់ដែលរស់នៅតំបន់ភាគខាងត្បូងបឹងទន្លេសាបបានចេញសេចក្តីថ្លែងការណ៍រួមគ្នាមួយពាក់ព័ន្ធនឹងសិក្ខាសាលាពិគ្រោះយោបល់ស្តីពីកម្មវិធីព្រៃឈើជាតិនេះដែលក្នុងនោះបង្ហាញពី សេចក្តីព្រួយបារម្ភ សេចក្តីត្រូវការ និង អនុសាសន៏ ឯសេចក្តីទាំងស្រុងភ្ជាប់ក្នុងតារាងឧសម្ព័ន្ធ។

## ៨. ការបិទអង្គសិក្ខាសាលា

បន្ទាប់ពីក្រុមនីមួយៗធ្វើបទបង្ហាញរួច លោក **ពិន ផាន់នី** នាយរងអធិការដ្ឋានរដ្ឋបាលព្រៃឈើខាងត្បូងបឹងបាន ឡើងធ្វើការបូកសរុបលទ្ធផលសិក្ខាសាលាដោយបញ្ជាក់ថា សិក្ខាសាលារយៈពេលពីរថ្ងៃប្រព្រឹត្តទៅដោយការយកចិត្តទុកដាក់ មានការចូលរួមមតិយ៉ាងផុសផុលជាពិសេស ការពិភាក្សាតាមក្រុម និង សំណួរ-ចម្លើយប្រកបដោយផ្លែផ្កា។

លោក **សៅ ដារឿន** អភិបាលស្រុក បាកាន នៃខេត្តពោធិ៍សាត់ តំណាងឱ្យសិក្ខាសាលាកាមបានឡើងធ្វើចំណាប់អារម្មណ៍ថា លោកមានមោទនៈភាពណាស់ដែលបានជ្រើសរើសយកខេត្តពោធិ៍សាត់ត្រូវបានជ្រើសរើសសំរាប់ការរៀបចំសិក្ខាសាលានេះ បញ្ហាគន្លឹះត្រូវបានយកមកពិភាក្សា ហើយ តួនាទីរបស់បណ្ដាអ្នកពាក់ព័ន្ធក្នុងវិស័យព្រៃឈើត្រូវបានរំលេច។ លោក បានបញ្ជាក់ទៀតថា ពីមុនច្បាប់ស្ដីពីព្រៃឈើ និង លិខិតបទដ្ឋាននានា ហើយ ឥឡូវយើងមានកម្មវិធីព្រៃឈើជាតិដែលផែនការគ្រប់គ្រងព្រៃឈើរយៈពេលវែងសង្ឃឹមថានាពេលអនាគតព្រៃឈើយើងនឹងត្រូវបានថែរក្សានៅគង់វង្សសំរាប់កូនចៅជំនាន់ក្រោយៗទៀត។

ជាចុងបញ្ចប់នៃពិធីសិក្ខាសាលា ឯកឧត្ដម **ទឹម ស៊ីផា** នាយអធិការដ្ឋានរដ្ឋបាលព្រៃឈើខាងត្បូងបឹងទន្លេសាប ដែលជាអធិបតីនៃអង្គសិក្ខាសាលា បានសំដែងនូវការកោតសរសើរ និង ថ្លែងអំណរគុណចំពោះក្រុមការងារដែលបានរៀបចំសិក្ខាសាលានេះប្រកបដោយភាព រលូន និងទទួលបានលទ្ធផលផ្លែផ្កាជាទីមោទនៈ និងសូមថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមទាំងអស់ផងដែរ។ គោលនយោបាយព្រៃឈើ គឺជាការកំណត់គោលដៅ និងស្វែងរកមាគ៌ាដើម្បីធ្វើឱ្យសំរេចនូវកម្មវិធីព្រៃឈើជាតិ ដែលជាគំរោងផែនការការងារផ្ដល់នូវយុទ្ធសាស្ត្រ និង ទិសដៅសំរាប់វិស័យព្រៃឈើក្នុងការធ្វើសមាហរណកម្មទៅនឹងវិស័យផ្សេងៗនៃសេដ្ឋកិច្ចជាតិ។ កម្មវិធីព្រៃឈើជាតិលើកស្ទួយការគ្រប់គ្រង ការប្រមូលផលប្រើប្រាស់ អភិរក្ស និងអភិវឌ្ឍន៍ព្រៃឈើឱ្យមាននិរន្តរភាព។ កម្មវិធីព្រៃឈើជាតិត្រូវធ្វើឱ្យមានលក្ខណៈទន់ភ្លន់ដូចពាក្យ **"សន្ទូចទន់អាចរ៉ៃត្រីធំបាន"**។ ហេតុដូច្នេះ ហើយបានជារដ្ឋបាលព្រៃឈើរៀបចំសិក្ខាសាលានេះឡើង ដើម្បីប្រមូលមតិយោបល់ អនុសាសន៍ និង សំណូមពររបស់ ឯកឧត្ដម លោក លោកស្រីទាំងអស់ រដ្ឋបាលព្រៃឈើស្វាគមន៍ទទួលយកដើម្បីពិនិត្យ និង ចាត់ថ្នាក់ទៅតាមមុខជំនាញនីមួយៗ។ ទទឹមនឹងនេះ ឯកឧត្ដម **ទឹម ស៊ីផា** ក៏បានបកស្រាយ និង បញ្ជាក់បន្ថែមចំពោះសំណូមពរដែលបានលើឡើងនៅក្នុងអង្គសិក្ខាសាលាផងដែរ។ នៅចុងបញ្ចប់ក៏បានបញ្ជាក់អំពីវិស័យព្រៃឈើនៅតែជាវិស័យអាទិភាពមួយដែលរួម ចំណែកក្នុងការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច បរិស្ថាន ពោលគឺព្រៃឈើជាប្រភពផ្ដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុង និង ក្បែរតំបន់ព្រៃឈើព្រមទាំងផ្ដល់នូវសុខមាលភាពដល់ប្រជាពលរដ្ឋទូទៅផងដែរ។

## ៩. សេចក្ដីសន្និដ្ឋាន

សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈស្ដីពីកម្មវិធីព្រៃឈើជាតិដែលបានធ្វើនៅថ្នាក់មូលដ្ឋាន ហើយ មានភាគីពាក់ព័ន្ធនៅមូលដ្ឋានចូលរួមមានសារៈសំខាន់ខ្លាំងណាស់ព្រោះជាឱកាសដែលបណ្ដាភាគីពាក់ព័ន្ធបានចូលរួមចំណែកបញ្ចេញ

មតិ យោបល់ និង ទស្សនៈក្នុងការរៀបចំឯកសារផែនការគ្រប់គ្រងព្រៃឈើរយៈពេលវែង។ សិក្ខាសាលាបានប្រព្រឹត្តិទៅប្រកបដោយបរិយាកាសយកចិត្តទុកដាក់ ស្និទ្ធិស្នាល និង ការពិភាក្សាពោរពេញទៅដោយផ្លែផ្កា ហើយ មតិ យោបល់ ទស្សនៈដែលលើកឡើងក្នុងឱកាសសិក្ខាសាលា ព្រមទាំងសេចក្តីថ្លែងការណ៍រួមគ្នារបស់សហគមន៍នៅតំបន់ខាងត្បូងបឹងទន្លេសាបនឹងចូលរួមចំណែកក្នុងការកែលំអឯកសារកម្មវិធីព្រៃឈើជាតិឱ្យរឹតតែប្រសើរថែមទៀត។

## ១០. អនុសាសន៍

មតិ យោបល់ ទស្សនៈនានាដែលលើកឡើងពេលសិក្ខាសាលា និង សេចក្តីថ្លែងការណ៍របស់សហគមន៍នៅតំបន់ខាងត្បូងបឹងទន្លេសាបដែលបញ្ជូនទៅអ្នកសម្របសម្រួលកម្មវិធីព្រៃឈើ រួមជាមួយលទ្ធផលពីសិក្ខាសាលានៅតំបន់បីផ្សេងទៀត គួរតែត្រូវបានយកទៅពិចារណាដោយក្រុមការងាររៀបចំកម្មវិធីព្រៃឈើជាតិ ដើម្បីដាក់បញ្ចូលទៅក្នុងឯកសារកម្មវិធីព្រៃឈើទៅតាមស្ថានភាព និង ចំណងទាក់ទងរបស់វា។

## ១១. តារាងឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី ១ : កម្មវិធីសិក្ខាសាលា
- ឧបសម្ព័ន្ធទី ២ : សន្ទរកថារបស់ឯកឧត្តមអភិបាលរងខេត្ត ពោធិ៍សាត់
- ឧបសម្ព័ន្ធទី ៣ : សេចក្តីសង្ខេបកម្មវិធីទី ៣ : ការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និង អភិបាលកិច្ច
- ឧបសម្ព័ន្ធទី ៤ : របាយការណ៍លទ្ធផលសិក្ខាសាលា
- ឧបសម្ព័ន្ធទី ៥ : សេចក្តីសង្ខេបបទបង្ហាញលទ្ធផលក្រុមពិភាក្សា
- ឧបសម្ព័ន្ធទី ៦ : រូបថតសកម្មភាពសិក្ខាសាលា
- ឧបសម្ព័ន្ធទី ៧ : សំណួរ-ចម្លើយដែលលើកឡើងក្នុងសិក្ខាសាលា
- ឧបសម្ព័ន្ធទី ៨ : សេចក្តីថ្លែងការណ៍របស់សហគមន៍ខាងត្បូងបឹងទន្លេសាប
- ឧបសម្ព័ន្ធទី ៩ : បញ្ជីឈ្មោះសមាជិកក្រុមពិភាក្សា
- ឧបសម្ព័ន្ធទី ១០ : បទបង្ហាញនៃកម្មវិធីព្រៃឈើជាតិទាំង ៦
- ឧបសម្ព័ន្ធទី ១១ : បទបង្ហាញលទ្ធផលតាមក្រុមពិភាក្សា

# សេចក្តីសង្ខេបលទ្ធផលពិភាក្សាតាមក្រុមនីមួយៗ

ដំណើរការនៃសិក្ខាសាលាប្រព្រឹត្តិទៅមានភាពរលូន ដោយមានសិក្ខាកាមសរុបចំនួន ១៥២ នាក់បានចុះឈ្មោះតាមក្រុម ឬកម្មវិធីពិភាក្សានីមួយៗ ដោយក្រុមទី១ ពិភាក្សាកម្មវិធីទី ១ មានសមាជិកចូលរួមចំនួន ២៦ នាក់ ក្រុមទី ២ មានសមាជិក ២១ នាក់ ក្រុមទី ៣ មានសមាជិកចូលរួមចំនួន ៣២ នាក់ ក្រុមទី ៤ មាន ៣៦ នាក់ ក្រុមទី ៥ មាន ១៣ នាក់ និង ក្រុមទី ៦ មានសមាជិកចំនួន ២៣ នាក់។

ក្រោយពេលពិភាក្សាបានលទ្ធផលរួចហើយក្រុមនីមួយៗបានឡើងធ្វើបទបង្ហាញ និង ឆ្លើយសំណួរទាក់ទងនឹងកម្មវិធីរបស់ខ្លួនដោយមានសមាជិកក្រុម និង អ្នកចងក្រងកម្មវិធីជួយសំរបសំរួលយ៉ាងអស់ពីលទ្ធភាព ធ្វើឱ្យបរយាកាសនៃសិក្ខាសាលាមានសភាពផុសផុលយ៉ាងខ្លាំង។

សេចក្តីសង្ខេបលទ្ធផលក្រុមពិភាក្សានីមួយៗមានដូចខាងក្រោម :

## ក្រុម១ : កម្មវិធីកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និង ការចុះបញ្ជិកា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

មានសមាជិកចំនួន ២៦ នាក់ តំណាងដោយលោកស្រី **ឡោន ស៊ីវី** មកពីសហគមន៍ព្រៃឈើក្បាលត្រាច ខេត្តពោធិ៍សាត់ ឡើងធ្វើបទបង្ហាញ ដែលបានពិភាក្សាលើប្រធានបទ :

**១. តើអ្នកយល់ដូចម្តេចចំពោះកម្មវិធី ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និង ការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍? គួរមានអនុកម្មវិធីអ្វីបន្ថែមទៀត?**

**កម្មវិធីនេះមានសារៈសំខាន់ :**

- មានព្រំប្រទល់ច្បាស់លាស់នៅទីវាលរវាងដីព្រៃ និងដីកសិកម្ម មានប្រយោជន៏ដល់សហគមន៍ ធ្វើឱ្យប្រជាពលរដ្ឋយល់ និង ចូលរួមអនុវត្ត
- ដើម្បីគ្រប់គ្រងព្រៃឈើឱ្យនៅគង់វង្ស អភិវឌ្ឍន៍ និងប្រើប្រាស់ដោយនិរន្តរភាព
- ទប់ស្កាត់រាល់បទល្មើស ការកាប់រានព្រៃឈើ កាត់បន្ថយជំលោះ ងាយស្រួលក្នុងការអនុវត្តច្បាប់
- អាជ្ញាធរមូលដ្ឋានចូលរួមដោយស្ម័គ្រចិត្ត ទើបការកំណត់ព្រំប្រទល់បានជោគជ័យ

**សំណូមពរចំពោះកម្មវិធី:**

- ចូលរួមដោយស្ម័គ្រចិត្តពីអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ
- ត្រូវសិក្សាអំពីការពាក់ព័ន្ធមុននឹងកំណត់ព្រំប្រទល់
- អញ្ជើញអ្នកពាក់ព័ន្ធមកដោះស្រាយមុននឹងកំណត់ព្រំប្រទល់
- ផ្សព្វផ្សាយដើម្បីឱ្យមានការចូលរួមសហការរវាងស្ថាប័នពាក់ព័ន្ធ និង ផ្តល់ពតិមានទៅវិញទៅមក

**២. បញ្ហាប្រឈម និងដំណោះស្រាយ ក្នុងការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍**

**ក.បញ្ហាប្រឈម**

- ព្រំប្រទល់រដ្ឋបាលឃុំ ស្រុក មិនច្បាស់លាស់

- ប្រជាជនមួយចំនួនរស់នៅកណ្តាលព្រៃ និងប្រជាជននៅជាប់ព្រំប្រទល់មិនបានចូលរួមពិតប្រាកដ
- ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធមិនបានច្បាស់លាស់
- បង្កើតភូមិថ្មីនៅក្នុងដីព្រៃ ដោយពុំមានច្បាប់អនុញ្ញាតពីក្រសួងមហាផ្ទៃ
- មានឈ្មួញនិង អ្នកមានអំណាចនៅពីក្រោយ
- ការចូលរួមរបស់អាជ្ញាធរមូលដ្ឋាននៅមានកំរិត(ប៉ះពាល់ផលប្រយោជន៍ពួកគាត់)
- ការចូលរួមរបស់ប្រជាជននៅមានកំរិត
- មានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន ភូមិ ឃុំ ស្រុក ភូមិបាលស្រុកក្នុងការកាន់កាប់ដីព្រៃឈើ
- ជនក្រីក្រខ្វះខាតដីលំនៅដ្ឋាន និងដីបង្កបង្កើនផល
- ការយល់ដឹងពីទ្រព្យសម្បត្តិរដ្ឋ និងឯកជនមិនច្បាស់លាស់
- មានការចេញប័ណ្ណកម្មសិទ្ធិលើដីព្រៃ
- មានការបំផ្លាញបង្គោលព្រំដែលបានបោះហើយពីជនខិលខូច
- ខ្វះការផ្សព្វផ្សាយទូលំទូលាយដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋ
- ខ្វះថវិកា
- ផែនទីគំរបព្រៃឆ្នាំ២០០២ មានការប៉ះពាល់លំនៅដ្ឋាន និងដីកសិកម្មប្រជាជន

**ខ. ដំណោះស្រាយ:**

- ផ្សព្វផ្សាយច្បាប់ដល់ប្រជាជនមូលដ្ឋានដែលមានដីពាក់ព័ន្ធ
- គួរមានការថវិកាគ្រប់ក្រាន់ និងថវិកាជួសជុលបង្គោលព្រំ
- ធ្វើការបដិសេធប័ណ្ណកម្មសិទ្ធិលើដីព្រៃឈើ
- អាជ្ញាធរមូលដ្ឋានគួរទប់ស្កាត់ប្រជាជនធ្វើពរនេចរ
- ធ្វើការប្រកាសផ្សព្វផ្សាយជាមុន មុនការកំណត់ព្រំ
- គួរមានស្ថាប័នបី ចូលរួម រដ្ឋបាលព្រៃឈើ ដែនដីនគរូបនីយកម្ម និងអាជ្ញាធរមូលដ្ឋាន

**៣. តើត្រូវធ្វើដូចម្តេចដើម្បីបង្កើនការកំណត់ព្រំព្រទល់សម្បត្តិព្រៃឈើ អចិន្ត្រៃយ៍សម្រេចបានឆាប់រហ័ស?**

- ដោះស្រាយទំនាស់ព្រំប្រទល់ជាមុន
- មានសម្ភារៈ ថវិកាគ្រប់គ្រាន់ និងទាន់ពេលវេលា មានកិច្ចសហប្រតិបត្តិការពីស្ថប័នពាក់ព័ន្ធ និងបង្កើតក្រុមការងារឱ្យបានឆាប់រហ័ស
- ត្រូវមានឆន្ទៈក្នុងការចូលរួម
- ត្រូវមានផែនការរួមសម្រាប់អ្នកពាក់ព័ន្ធ
- បង្កើនការដោះមីនពីដីព្រៃ

**៤. តើអាជ្ញាធរ សហគមន៍ និងប្រជាជនមូលដ្ឋានចូលរួម ដូចម្តេចក្នុងការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍?**

- ចូលរួមដោយស្ម័គ្រចិត្ត និង មានសុឆន្ទៈ
- ថែទាំបង្គោលព្រំ
- ចូលរួមផ្សព្វផ្សាយច្បាប់
- កំណត់ពេលវេលាឱ្យបានច្បាស់
- ចូលរួមបញ្ជាក់ទីតាំងឱ្យបានច្បាស់
- តាមដានសកម្មភាពបំផ្លាញបង្គោលព្រំ
- ផ្តល់ព័ត៌មានដល់សមត្ថកិច្ចពេលជួបហេតុការណ៍
- ចលនាមហាជន ចូលរួមកំណត់ព្រំ
- ចូលរួមបញ្ចេញពលកម្ម និង គាំទ្រកម្មវិធី

**៥. តើត្រូវមានស្ថាប័នពាក់ព័ន្ធអ្វីខ្លះចូលរួមក្នុងការចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍?**

- អាជ្ញាធរ
- ប្រជាជនរស់នៅជិតដំបន់ព្រៃ
- រដ្ឋបាលព្រៃឈើ
- បរិស្ថាន
- ព្រឹទ្ធាចារ្យ
- ដែនដីនគរូបនីយកម្ម
- សហគមន៍
- អធិការកិច្ចខេត្ត

## ក្រុម ២ : កម្មវិធីគ្រប់គ្រងធនធានព្រៃឈើជាតិ និង ការអភិរក្ស

មានសមាជិកចូលរួមចំនួន ២១ នាក់ និង តំណាងដោយលោក **ឡំ សោម** ជាអភិបាលស្រុក មោងឫស្សី ឡើងធ្វើបង្ហាញ និង បានពិភាក្សាលើអនុកម្មវិធីចំនួន ០៨ ដូចខាងក្រោម :

**អនុកម្មវិធីទី១ : ការរៀបចំផែនការគ្រប់គ្រងព្រៃឈើជាតិ**

- ការរៀបចំផែនការគ្រប់គ្រងព្រៃឈើជាតិត្រូវមានទិន្នន័យពីមូលដ្ឋាន និងថ្នាក់ជាតិ ការចូលរួមយោបល់ពីអ្នកពាក់ព័ន្ធ ស្របតាមស្ថានភាពជាក់ស្តែង និងទម្រង់ច្បាប់ជាលក្ខណៈជាតិស្របតាមស្តង់ដាអន្តរជាតិរយៈពេលមធ្យម ៥ ឆ្នាំ និង រយៈពេលវែង ២០ ឆ្នាំ និងមានការពិគ្រោះយោបល់ក្នុងដំណើរការរៀបចំ ។

**អនុកម្មវិធីទី២ : សារពើភ័ណ្ឌព្រៃឈើជាតិ**

២.១ : សារពើភ័ណ្ឌព្រៃឈើជាតិ

- ភាពសមស្របក្នុងការធ្វើសារពើភ័ណ្ឌព្រៃឈើជាតិ ៥ឆ្នាំម្តង ដោយប្រមូលទិន្នន័យប្រភេទឈើ ប្រភេទផល-អនុផលព្រៃឈើ ក៏រិតលូតលាស់ ដង់ស៊ីតេ ជីវចំរុះនិងប្រព័ន្ធអេកូឡូស៊ី ដី សីតុណ្ហភាព និងសេដ្ឋកិច្ចសង្គម។
- ដើម្បីឱ្យការធ្វើសារពើភ័ណ្ឌព្រៃឈើជាតិទទួលបានលទ្ធផលល្អប្រសើរ យើងត្រូវមានឧបករណ៏គ្រប់គ្រាន់ បែងចែកតំបន់ប្រភេទព្រៃផ្សេងគ្នាធៀបនឹងការលូតលាស់តាមប្រភេទនីមួយៗ ប្រព័ន្ធព័ត៌មានវិទ្យា តាំងឡូត៏គំរូស្របតាមស្តង់ដា និងវិភាគទិន្នន័យដើម្បីតាមដានវាយតម្លៃការប្រែប្រួលធនធានព្រៃឈើ។

២.២ : ទម្រង់តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៏ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

វិធីសាស្ត្រត្រួតពិនិត្យវាយតម្លៃនិងរបាយការណ៏រួមមានៈ

- ប្រមូលឯកសារនិងទិន្នន័យនៅទីវាល
- ការហោះហើរពិនិត្យពីលើអាកាស
- សំភាសន៏ប្រជាជន ចូលពិនិត្យផ្ទាល់
- បញ្ជីសារពើភ័ណ្ឌ និងធ្វើស្ថិតិគំរូវការប្រើប្រាស់របស់មូលដ្ឋាន
- ត្រូវមានយន្តការរវាងស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រង
- បែងចែកតំបន់ទទួលខុសត្រូវឱ្យសមស្រប
- ប្រជុំជារៀងរាល់ខែ រួចធ្វើការពិគ្រោះយោបល់ដែលអនុវត្ត
- បញ្ចេញរបាយការណ៏ជាសាធារណៈ
- ធ្វើការតាមដាន ត្រួតពិនិត្យ វាយតំលៃនិងរបាយការណ៏ពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព

ប្រភពទិន្នន័យដែលអាចយកមកធ្វើការតាមដាន ពិនិត្យ វាយតម្លៃ និងធ្វើរបាយការណ៏រួមមាន :

- ធនធានព្រៃឈើ ជីវចំរុះ ការលូតលាស់ព្រៃឈើ មជ្ឈដ្ឋាន អាកាសធាតុ សេដ្ឋកិច្ច និងសង្គម
- កាលបរិច្ឆេទនិងពេលវេលា និងកត្តាឧបសគ្គ
- ចំនុចខ្លាំង ចំនុចខ្សោយ នៃការអភិវឌ្ឍ ការគ្រប់គ្រង បរិមាណ គុណភាព ទំនាស់ បញ្ហា មូលហេតុ ដំណោះស្រាយ និងបទពិសោធន៏

ប្រសិទ្ធិភាពនៃការតាមដាន ពិនិត្យ វាយតម្លៃ និងរបាយការណ៏

- វិធីសាស្ត្រនៃការគ្រប់គ្រងព្រៃឈើ
- សិក្ខាសិលា និងផ្សព្វផ្សាយដល់មូលដ្ឋានឱ្យបានទូលំទូលាយនូវច្បាប់ស្តីពីព្រៃឈើ និងសារៈប្រយោជន៏នៃព្រៃឈើ

- សហការណ៍ជាមួយអាជ្ញាធរនិងសហគមន៍មូលដ្ឋានដែលនៅជិតបំផុតរាល់ដំណោះស្រាយបញ្ហាផ្សេងៗ
- ទិន្នន័យទីវាល និងផ្កាយរណប
- មានការវាយតម្លៃដោយឯករាជ្យ

**អនុកម្មវិធីទី៣ : ការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងព្រៃបម្រុងទុកអចិន្ត្រៃយ៍ក្រៅពីព្រៃសហគមន៍**

ប្រព័ន្ធគ្រប់គ្រងមានសារៈប្រយោជន៍ រួមមានៈ ធនធានព្រៃឈើ ពូជឈើ ជំរកសត្វ ជីវចំរុះ ការពារបរិស្ថាន និយ័តកម្មប្រភពទឹក ស្តុកកាបូន ទេសចរណ៍ធម្មជាតិ ស្រាវជ្រាវវិទ្យាសាស្ត្រ មានការចូលរួមវិនិយោគលើវិស័យព្រៃឈើ និងផ្តល់ប្រយោជន៍ដល់សេដ្ឋកិច្ចនិងសង្គម ដោយចូលរួមកាត់បន្ថយជីវភាពប្រជាជន។

វិធីសាស្ត្រក្នុងការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រង រួមមានៈ

- ធ្វើផែនទី និងកំណត់ព្រំឱ្យបានច្បាស់លាស់
- រៀបចំព្រៃតាមមុខងារ
- បង្កើនការងារដាំឈើបន្ថែម
- គ្រប់គ្រងនិងអភិរក្សព្រៃឈើ
- ត្រូវទុកបំរុងសម្រាប់តម្រូវការរបស់សហគមន៍ និងត្រូវមានការប្រើប្រាស់ឱ្យបានច្បាស់ដូចជាការប្រើប្រាស់របស់សហគមន៍ផងដែរ
- ត្រូវធ្វើការដេញថ្លៃជាសាធារណៈមុននឹងផ្តល់សិទ្ធិដល់ក្រុមហ៊ុនឯកជន
- រៀបចំផែនការឱ្យបានច្បាស់លាស់
- ត្រូវធ្វើការសិក្សាស្រាវជ្រាវ ធ្វើសារពើភ័ណ្ឌ និងតាមដាន ៣ ឆ្នាំម្តង និងគ្រប់គ្រងទិន្នន័យ
- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ
- ផាកពិន័យ និងផ្តន្ទាទេសជនល្មើស និងអ្នកឃុបឃិត
- ត្រួតពិនិត្យជាប្រចាំ និងគ្រប់គ្រងឱ្យជាក់លាក់

ដើម្បីទទួលបានប្រសិទ្ធិភាពនៃប្រព័ន្ធគ្រប់គ្រង យើងគួរអនុវត្តដូចខាងក្រោមៈ

- កំណត់ព្រំប្រទល់ដោយមានការបោះបង្គោលព្រំ និងធ្វើសារពើភ័ណ្ឌព្រៃឈើ
- រៀបចំក្រុមបច្ចេកទេសតាមស្តង់ដាតំបន់
- រៀបចំផែនការគ្រប់គ្រង ដោយមានការចូលរួមពីស្ថាប័នដែលពាក់ព័ន្ធ និងពិគ្រោះយោបល់
- ធ្វើការអប់រំប្រជាជន និងអ្នកពាក់ព័ន្ធ
- ជំរុញការគ្រប់គ្រង ដកហូត ប្រគល់ភារកិច្ចជូនសង្កាត់ និងផ្នែករដ្ឋបាលព្រៃឈើដើម្បីគ្រប់គ្រង និងទទួលខុសត្រូវ

- តាមដាន វាយតម្លៃ ការពារ និងផ្តល់ព័ត៌មាន
- ធ្វើរបាយការណ៍ឱ្យបានច្បាស់ពីប្រព័ន្ធនៃការគ្រប់គ្រងនេះ និងលើកវិធានការដាក់ស្តែងក្នុងការអនុវត្ត និងដកបទពិសោធន៍ដែលបានធ្វើកន្លងមក

**អនុកម្មវិធីទី៤ : ការអភិរក្សធនធានសេនេទិច និងបង្កើតប្រភពគ្រាប់ពូជសម្រាប់កម្មវិធីដាំឈើ**

ជម្រុញ ពង្រឹង និងលើកទឹកចិត្តការអភិរក្សធនធានសេនេទិចព្រៃឈើរួមមាន :

- ដាក់ផែនការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ
- ត្រូវកំណត់តំបន់ប្រភពធនធានសេនេទិក
- ផ្សព្វផ្សាយអំពីចំណេះដឹងធនធានសេនេទិកឱ្យបានស៊ីជំរៅនឹងទូលំទូលាយ និងមានទស្សនៈកិច្ចសិក្សា
- បណ្តុះបណ្តាលជំនាញបច្ចេកទេស
- ផ្តល់សេវាទទួលទិញគ្រាប់ពូជពីតំបន់របស់សហគន៏ និងទីផ្សារគ្រាប់ពូជ
- ត្រូវបំផុសចលនាអភិរក្ស និងរក្សាគ្រាប់ពូជឈើដូចជា ខ្លុង ត្បែង រាំង ក្រញូង យូអង្ហែង
- រកដៃគូគាំទ្រ និងមានថវិកាដល់ប្រជាជនមូលដ្ឋានដើម្បីគ្រប់គ្រងធនធានសេនេទិក
- ត្រូវជំរុញនិងពង្រឹងការលើកទឹកចិត្តរបស់សហគមន៏មូលដ្ឋាន មន្ត្រីជំនាញ ស្ថាប័នពាក់ព័ន្ធឱ្យបានល្អ អ្នកអនុវត្តផ្ទាល់ និង ដៃគូអភិវឌ្ឍន៏
- ពង្រឹងការអនុវត្តច្បាប់

ស្ថាប័នចូលរួមៈ រដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថានក្រសួងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួង មហាផ្ទៃ វិទ្យាស្ថានស្រាវជ្រាវ អាជ្ញាធរដែនដី សហគមន៏មូលដ្ឋាន ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ វិស័យឯកជន និងសង្គមស៊ីវិល។

ផលប្រយោជន៏ទទួលបានពីការអភិរក្សធនធានសេនេទិចព្រៃឈើ មានដូចខាងក្រោមៈ

- មានព្រៃពូជឈើក្នុងស្រុក
- កាត់បន្ថយថវិកាទិញគ្រាប់ពូជពីក្រៅស្រុក
- ពង្រីកការដាំពូជឈើដែលមានគុណភាពល្អ
- ទប់ស្កាត់ការហូរច្រោះ កាត់បន្ថយកំដៅ ជំរកសត្វ រក្សានូវប្រព័ន្ធជីវចំរុះ ប្រព័ន្ធអេកូឡូស៊ី បរិស្ថានល្អ
- ជួយជីវភាពប្រជាជន កាត់បន្ថយភាពក្រីក្រ

**អនុកម្មវិធីទី៥ : អភិវឌ្ឍពហុចំការដាំឈើ**

លើកទឹកចិត្តក្នុងការជម្រុញការបង្កើតចំការឈើប្រើប្រាស់ច្រើនយ៉ាង រួមមានៈ

- លើកទឹកចិត្តឱ្យដាំជាលក្ខណៈឯកជនដោយផ្តល់ដីឱ្យឯកជនឬសហគន៏ចូលរួមដាំ និងការកាត់បន្ថយពន្ធឈើដាំរបស់សហគមន៏មូលដ្ឋាន

- ធ្វើការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសដាំឈើ និងគ្រប់គ្រងចំការព្រៃដាំដល់សហគមន៍
- ជួយស្វែងរកដៃគូអភិវឌ្ឍន៍ និងរកទីផ្សារ
- មានការគាំទ្រពីស្ថាប័នពាក់ព័ន្ធលើការងារដាំឈើ និងផ្តល់សេវាកម្មបច្ចេកទេសដាំឈើពីសំណាក់មន្ត្រីរដ្ឋបាលព្រៃឈើ
- គោរពគោលការណ៍ប្រព័ន្ធអេកូឡូស៊ី និងការប្រើប្រាស់តាមប្រពៃណី

ធ្វើឱ្យមានតុល្យភាពផលប្រយោជន៍នៃចំការឈើដាំប្រើប្រាស់ច្រើនយ៉ាង

- បង្កើនគំរបព្រៃ និងជម្រកសត្វព្រៃ បង្កឱ្យមានបរិស្ថានល្អ ដីមានជីជាតិ
- មានពូជឈើល្អដល់មនុស្សជំនាន់ក្រោយ ជាផល អនុផលព្រៃឈើ (របងការពារភូមិដ្ឋាន អុសដុត ឱសថ.....)
- ផ្តល់ប្រយោជន៍សង្គម និងលើកស្ទួយជីវភាពសហគមន៍មូលដ្ឋានដោយទទួលបានប្រាក់ចំណូលពីចំការឈើ
- បំផុសឆន្ទៈចូលរួមការពារព្រៃឈើ
- តំបន់ទេសចរណ៍ធម្មជាតិ
- បំរើផ្នែកឧស្សាហកម្ម

**អនុកម្មវិធីទី៦ : ការរៀបចំប្រព័ន្ធគ្រប់គ្រងព្រៃការពារ រួមមានការអភិរក្សធនធានជីវៈចំរុះ និងការអភិវឌ្ឍន៍ទេសចរណ៍**

ការប្រឈម ចំពោះការអភិរក្សព្រៃឈើ សត្វព្រៃ និងជីវៈចំរុះរួមមានៈ

- សមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើ និងបទពិសោធន៍នៅមានកំរិត
- ការកាប់ឈើយ៉ាងអនាធិបតេយ្យ និងបទល្មើសព្រៃឈើសត្វព្រៃនៅកើតមាន
- ខ្វះមធ្យោបាយ និងថវិកាមានកំរិត
- មិនទាន់មានការចូលរួមរបស់សហគមន៍ឱ្យបានទូលំទូលាយ
- ការផ្សព្វផ្សាយអប់រំនៅតាមតំបន់នៅមានកំរិត
- ជម្រុញ និងពង្រឹងប្រព័ន្ធគ្រប់គ្រង ការពារ អភិរក្សជីវចំរុះ និងទេសចរណ៍ធម្មជាតិឱ្យមាននិរន្តរភាព
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង
- ការកំណត់ព្រំប្រទល់ច្បាស់លាស់
- ពង្រឹងប្រព័ន្ធគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព
- បង្កើនសមត្ថភាពដល់មន្ត្រីគ្រប់គ្រង
- រដ្ឋបាលព្រៃឈើត្រូវសហការជាមួយសហគន៍មូលដ្ឋាន និងអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងទៀត
- មានការលើកទឹកចិត្តដល់សហគមន៍ក្នុងការចូលរួម
- ទាក់ទាញភ្ញៀវទេសចរណ៍ឱ្យមកទស្សនានៅតំបន់ទេសចរណ៍ធម្មជាតិ

- ត្រូវរក្សាលក្ខណៈធម្មជាតិឱ្យបានច្រើន និងកែច្នៃបន្តិចបន្តួច
- ការចុះត្រួតពិនិត្យស្រាវជ្រាវព័តមានថ្មីៗ
- បង្កើតព្រៃសហគមន៍
- បង្កើនការផ្សព្វផ្សាយ អប់រំស្តីពីច្បាប់ព្រៃឈើ និងសារៈប្រយោជន៍នៃជីវចំរុះ។

ផលប្រយោជន៍របស់សហគមន៍មូលដ្ឋានទទួលបានពីការការពារ ការអភិរក្សជីវៈចំរុះ និងទេសចរណ៍ធម្មជាតិ :

- ប្រភពចំណូលដល់សហគមន៍មូលដ្ឋាន តាមរយៈការផ្តល់ការងារ និងបង្កើតមុខរបរដល់ប្រជាជន
- ចំណូលពីទេសចរណ៍ធម្មជាតិ
- ការពារបាននូវបរិស្ថាន ប្រព័ន្ធអេកូឡូស៊ី និយ័តភាពប្រភពទឹកសំរាប់វិស័យកសិកម្ម និងសុខមាលភាពរបស់ប្រជាជនមូលដ្ឋាន
- មានលំនឹងធម្មជាត
- សេដ្ឋកិច្ច សង្គមរីកចំរើន
- ធ្វើឱ្យផ្លាស់ប្តូរឥរិយាបថពីមុន និងមានកិត្តិយសសំរាប់សហគមន៍មូលដ្ឋាន
- ផ្តល់ការសិក្សាស្រាវជ្រាវ

**អនុកម្មវិធីទី៧ : ការកែច្នៃផលិតផលឈើ និងទីផ្សារ**

ពង្រឹងការកែច្នៃផលអនុផលព្រៃឈើ រួមមាន :

- ត្រួតពិនិត្យឱ្យច្បាស់លាស់ពីគុណភាពផលិតផលកែច្នៃ
- សេវាសាធារណៈត្រូវបានកែលំអ
- ផ្តល់បច្ចេកវិជ្ជាថ្មី និងទំនើប
- ធានាការប្រកួតប្រជែង
- ស្ថាប័នជំនាញផ្តល់វិធីសាស្ត្រកែច្នៃ
- គិតគូអំពីបរិមាណអាយុកាលផលអនុវផលព្រៃឈើឱ្យបានច្បាស់ដើម្បីឱ្យមាននិរន្តរភាព
- ដកហូតប្រើប្រាស់តាមបច្ចេកទេសត្រឹមត្រូវ
- រៀបចំបទដ្ឋានគ្រប់គ្រង
- សិក្សាតំរូវការទីផ្សារ
- រកដំណោះស្រាយប្រភពផលអនុផលព្រៃឈើ
- បន្ថយពន្ធលើផលអនុផលព្រៃឈើឱ្យសមស្របដល់សហគមន៍
- លើកទឹកចិត្តដល់ការកែច្នៃ

ពង្រឹងផលិតផលកែច្នៃក្នុងស្រុកនិងរកទីផ្សារ :

- ទំនាក់ទំនងក្រុមហ៊ុន ស្ថាប័ន ដែលធានាគុណភាព ផលិតផលកែច្នៃ និងសោភ័ណភាព
- ផលិតផលមានលក្ខណៈវប្បធម៌ និងប្រពៃណីជាតិ
- ចងក្រងសហគមន៍កែច្នៃផលិតផល
- ស្វែងរកដៃគូគាំទ្រ និងព័ត៌មានទីផ្សារ
- រក្សាគុណភាព និងតម្លៃ

ការកែច្នៃផលិតផលឈើដោយដៃ និងម៉ាស៊ីនស្វ័យប្រវត្តិផ្ដល់សក្ដានុពលដល់ការអភិវឌ្ឍផលិតផលឈើ :

**ដោយដៃ**

- រក្សាលក្ខណៈជាតិនិយម ( ក្បាច់ រចនា លើការកែច្នៃ )
- ផ្ដល់ការងារដល់ប្រជាជន
- ពេញនិយមពីភ្ញៀវទេសចរណ៍
- រក្សាតំលៃផលិតផល
- មានចំណេះដល់កូនខ្មែរ

**ម៉ាស៊ីនស្វ័យប្រវត្តិ**

- មានលក្ខណៈជាខ្សែចង្វាក់ផលិតកម្ម
- សន្សំសំចៃ
- ជឿនលឿន រហ័ស និងទំនើប

**អនុកម្មវិធីទី៨ : ការអភិវឌ្ឍន៍បច្ចេកវិជ្ជាឈើ និងការកែច្នៃ**

ផ្ដល់ប្រយោជន៍ដល់សហគមន៍មូលដ្ឋាន ដៃគូអភិវឌ្ឍ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ :

- បណ្ដុះបណ្ដាលបច្ចេកទេស ទស្សនៈកិច្ច
- ទីផ្សារលក់ផលិតផល
- អភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយភាពក្រីក្រ
- សេដ្ឋកិច្ចជាតិកើនឡើង
- មានចំណេះដឹង និង ប្រជាជនមានការងារធ្វើ

ដៃគូអភិវឌ្ឍការកែច្នៃឈើ និងបច្ចេកវិជ្ជាឈើ :

- ក្រុមអ្នកវិនិយោគខាងក្នុង និងក្រៅប្រទេស

- វិស័យឧស្សាហកម្ម
- សហគន៍មូលដ្ឋាន
- រដ្ឋបាលព្រៃឈើ
- អង្គការដៃគូរ
- អាជ្ញាធរមូលដ្ឋាន
- ក្រសួង វប្បធម៌ ឧស្សាហកម្ម កសិកម្ម និងហិរញ្ញវត្ថុ
- សង្គមស៊ីវិល
- NGO

## ក្រុម៣ : កម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ច

ក្រុមនេះមានសមាជិកចំនួន ៣៣ នាក់ មានលោក **ហោ សំអាត** មកពីសហគមន៍នេសាទ ខេត្ត បាត់ដំបងឡើងធ្វើបទបង្ហាញដែលបានធ្វើការពិភាក្សាលើចំណុចសំខាន់ៗដូចខាងក្រោម :

**អនុកម្មវិធីទី ១ : ការពង្រឹងការអនុវត្តច្បាប់ និង អភិបាលកិច្ច**

**តើមូលហេតុចំបងអ្វីខ្លះដែលនាំឱ្យធនធានព្រៃឈើថយចុះ?**

- o ការផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងការអនុវត្តច្បាប់ពុំទាន់មានប្រសិទ្ធភាព
- o កំណើនប្រជាជន កំណើនតំរូវការប្រើប្រាស់ធនធានព្រៃឈើ និងដីបង្កបង្កើនផល
- o មន្ត្រីរដ្ឋបាលព្រៃឈើមានចំនួនតិច ខ្វះមធ្យោបាយ សំភារៈ និង ថវិកាបំពេញ ការងារ
- o កិច្ចសហការទប់ស្កាត់បទល្មើសព្រៃឈើពីគ្រប់ភាគីពាក់ព័ន្ធនៅមានកំរិត
- o ភាពក្រីក្រ ចំណាកស្រុក ការផ្លាស់ទៅតាំងទីលំនៅថ្មីក្នុងដែនព្រៃ
- o ក្រុមហ៊ុនដែលបានទទួលកិច្ចសន្យាពីរាជរដ្ឋាភិបាលក្នុងការវិនិយោគដីសម្បទាន សេដ្ឋកិច្ចមិនគោរពកិច្ចសន្យា

**តើនរណាខ្លះដែលទទួលផលប្រយោជន៍ពីធនធានព្រៃឈើ?**

- o ប្រជាពលរដ្ឋ និងសហគមន៍ដែលរស់នៅ តំបន់ព្រៃ
- o មន្ត្រីរដ្ឋបាលព្រៃឈើ
- o វិនិយោគិន
- o សង្គមស៊ីវិល
- o ទេសចរជាតិ និងអន្តរជាតិ

**តើភាគីពាក់ព័ន្ធណាខ្លះដែលគួរចូលរួមក្នុងការពង្រឹងការអនុវត្តច្បាប់ និងអភិបាលកិច្ច ហើយមានតួនាទីអ្វីខ្លះ?**

- **អាជ្ញាធរដែនដី ៖** ទប់ស្កាត់ការទិញ-លក់ និងបញ្ឈប់ការចេញពាក្យកាន់កាប់ដីព្រៃ សហការជាមួយជំនាញរដ្ឋបាលព្រៃឈើក្នុងការធ្វើផែនការគ្រប់គ្រងព្រៃឈើ ទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ និងការពារធនធានព្រៃឈើ
- **សហគមន៍មូលដ្ឋាន ៖** ចូលរួមពិភាក្សាលើសកម្មភាពពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យព្រៃឈើ ដូចជាការធ្វើផែនការ ការពិគ្រោះយោបល់ ការផ្សព្វផ្សាយ ការផ្តល់ពត៌មាន ចូលរួមទប់ស្កាត់ និងបង្ក្រាប ការពារភ្លើងឆេះព្រៃ បញ្ឈប់សកម្មភាពកាប់រានដីព្រៃ
- **កងកំលាំងប្រដាប់អាវុធ ៖** ផ្តល់កំលាំងសហការ និងបង្ក្រាបបទល្មើសព្រៃឈើជាក់ស្តែង ការពារវត្ថុតាងបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងផ្តល់ពត៌មានបទល្មើសព្រៃឈើ
- **ប្រព័ន្ធពត៌មាន ៖** ផ្តល់ពត៌មានពីបទល្មើសព្រៃឈើទាន់ពេលវេលាទាំងវិជ្ជមាន និងអវិជ្ជមាន បទពិសោធន៍ និងការអប់រំផ្សព្វផ្សាយពីច្បាប់ និងលិខិតបទដ្ឋាន
- **សង្គមស៊ីវិល ៖** អប់រំផ្សព្វផ្សាយ ជួយសំរបសំរួល គាំទ្រ និងសហការជាមួយជំនាញ អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ
- **ស្ថាប័នសាសនា ៖** អប់រំ ផ្សព្វផ្សាយ ថែរក្សា ចូលរួមក្នុងការងារសហគមន៍ ព្រៃឈើ និង ការដាំដើមឈើ
- **ស្ថាប័នតុលាការ ៖** វិនិច្ឆ័យ បើកសវនាការ ចាត់ការតាមនីតិវិធីច្បាប់លើ សំណុំរឿងបទល្មើសទាន់ពេលវេលា
- **វិស័យអប់រំ ៖** បញ្ចូលកម្មវិធីអភិរក្ស និងអភិវឌ្ឍន៍ធនធានព្រៃឈើក្នុងកម្ម វិធីសិក្សា
- **រដ្ឋបាលព្រៃឈើ ៖** ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋាន រៀបចំផែនការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ ពង្រឹង និងការអនុវត្តច្បាប់

**តើអភិបាលកិច្ចល្អក្នុងវិស័យព្រៃឈើមានអ្វីខ្លះ?**

- តម្លាភាព គណនេយ្យភាព និង សេវាកម្ម
- ចូលរួមសហការដោយស្មោះស្ម័គ្រ
- និរន្តរភាព ប្រសិទ្ធភាព
- អប់រំ ផ្សព្វផ្សាយជាសាធារណៈ

**តើត្រូវមានវិធានការយ៉ាងណាដើម្បីទប់ស្កាត់ និងដោះស្រាយចំពោះបុគ្គលដែលបានតាំងទីលំនៅ និង យកដីព្រៃរបស់រដ្ឋ?**

- ត្រួតពិនិត្យរដ្ឋបាលជាប្រចាំ
- ទប់ស្កាត់ការតាំងទីលំនៅ រានដីព្រៃថ្មីៗធ្វើចំការបន្ត
- ត្រូវតាមដាន និង ធ្វើស្ថិតិអ្នកគ្មានដីពិតប្រាកដ ដើម្បីពិនិត្យផ្តល់ដីសម្បទានសង្គមកិច្ចប្រកបដោយតម្លាភាព និងយុត្តិធម៌

- ចាត់វិធានការតាមផ្លូវច្បាប់ចំពោះអ្នកបំផុស អ្នកនៅពីក្រោយ និង ជនឆ្លៀតឱកាស
- បោះបង្គោលព្រំដីព្រៃរបស់រដ្ឋឱ្យបានច្បាស់លាស់
- ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋាននានាឱ្យបានទូលំទូលាយ
- ចាត់វិធានការដកហូតដីព្រៃមកវិញចំពោះអ្នកដែលរំលោភកាន់កាប់ដីព្រៃខុសច្បាប់

**អនុកម្មវិធីទី ២ : ការពង្រឹងការអនុវត្តច្បាប់ និង រាយការណ៍ពី ឧក្រិដ្ឋកម្មព្រៃឈើ**

**តើមធ្យោបាយផ្សព្វផ្សាយណាខ្លះដើម្បីបង្កើនការយល់ដឹងជាសាធារណៈអំពីច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋាននានាឱ្យមានប្រសិទ្ធភាពខ្ពស់?**

- បង្កើនការផ្សព្វផ្សាយឱ្យបានទូលំទូលាយស៊ីជំរៅដោយផ្ទាល់ និងប្រយោល
- **ផ្ទាល់ :** ប្រជុំ សិក្ខាសាលា ការបណ្តុះបណ្តាល សំដែងសិល្បះ ចែករូបត្លុក ផ្សព្វផ្សាយ
- **ប្រយោល :** ប្រព័ន្ធផ្សព្វផ្សាយវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី ផ្ទាំងប៉ាណូ លិខិតបទដ្ឋានផ្សេងៗ អ៊ីនធ័រណែត

**អនុកម្មវិធីទី ៣ : ការឆ្លើយតបរហ័សចំពោះពត៌មានបទល្មើសព្រៃឈើ**

**ការផ្តល់ពត៌មានបទល្មើសព្រៃឈើ**

- តាមទូស័ព្ទ វិទ្យុទាក់ទង
- ផ្ទាល់មាត់
- របាយការណ៍ជាក់ស្តែង
- សារពត៌មាន
- លិខិតអនាមិក លិខិតសំងាត់
- ជំនាញត្រូវមានលេខទូរស័ព្ទទទួលពត៌មាន(ទូរស័ព្ទអ្នកហៅចូលមិនបង់ប្រាក់)
- សារជាសំឡេង សារជាអក្សរ អ៊ីមែល គេហទំព័រ

## ក្រុម ៤ : សហគមន៍ព្រៃឈើ

សមាជិកចូលរួមក្នុងក្រុមនេះមានចំនួន ៣៦ នាក់ និង មានព្រះតេជគុណព្រះនាម **វ៉ាន់ សុឃីម** តំណាងមកពីសហគមន៍ព្រៃឈើ ឃុំ ពោធិ៍ ខេត្ត កំពង់ឆ្នាំង ធ្វើបទបង្ហាញលទ្ធផលដែលក្រុមបានពិភាក្សាលើប្រធានបទ :

**គួរមានអនុកម្មវិធីលើកទឹកចិត្តដល់សហគមន៍ព្រៃឈើ**

- ផ្តល់ថវិកាសំរាប់អភិវឌ្ឍន៍សហគមន៍
- ផ្តល់ប័ណ្ណសរសើរលើកទឹកចិត្តសហគមន៍ និង អ្នកពាក់ព័ន្ធ
- ផ្តល់សេវាកម្មឱ្យមានពេលវេលាសកម្មភាពគ្រប់គ្រងព្រៃសហគមន៍

**គួរមានអនុកម្មវិធីសហគមន៍ និង ការកែលំអតំបន់ទេសចរណ៍**

**ចំពោះសកម្មភាពក្នុងអនុកម្មវិធីនាំងបី នៃកម្មវិធីសហគមន៍ព្រៃឈើរួមមាន :**

**សកម្មភាពក្នុងអនុក្មវិធីទី ១ មាន**

- ពិធីបំបួសព្រៃឈើ
- ការទប់ស្កាត់ និង កាតបន្ថយមហន្តរាយដែលកើតឡើងរៀងរាល់ឆ្នាំ គឺ ភ្លើងឆេះព្រៃ

**សកម្មភាពក្នុងអនុក្មវិធីទី ២ មាន**

- បង្កើតថ្នាលបណ្តុះកូនឈើនៅក្នុងសហគមន៍
- លើកទឹកចិត្តជាប្រាក់ឧបត្ថម្ភ សហគមន៍ព្រៃឈើក្នុងការគ្រប់គ្រងព្រៃសហគមន៍

**សកម្មភាពក្នុងអនុក្មវិធីទី ៣ មាន**

- បង្កើតបណ្តាញឱ្យមានគ្រប់ស្ថាប័នចូលរួមដើម្បីពង្រឹង និង គាំទ្រការងារសហគមន៍ព្រៃឈើ
- រៀបចំប្រជុំប្រចាំត្រីមាស
- ផាកពិន័យ ឬចាប់ឃាត់
- ប្រមូលឯកសារ និងពតិមានសំខាន់ៗនៅក្នុងសហគមន៍
- បង្កើតប៉ុស្តិ៍យាមក្នុងព្រៃសហគមន៍
- បង្កើតក្រុមការពារព្រៃសហគមន៍

**<u>សំណូមពរ</u> :សុំដកជំហ៊ានទី ០៩ នៅក្នុងអនុកម្មវិធីទី១ មកដាក់ក្នុងអនុកម្មវិធីទី ២វិញ។**

សកម្មភាពសំខាន់ៗ ដែលស្នើសុំសំរាប់អនុវត្តក្នុងរយៈពេល ៥ ឆ្នាំដំបូងរួមមាន :

- កំណត់តំបន់សក្កានុពលឱ្យបានឆាប់
- ជំរុញឱ្យមានការទទួលស្គាល់សហគមន៍ព្រៃឈើឱ្យបានឆាប់
- កំណត់ព្រំប្រទល់ព្រៃសហគមន៍ និងផែនទីព្រៃ
- ផ្តល់ចំណេះដឹង ឬបង្កើនសមត្ថភាព និងផ្សព្វផ្សាយ
- ជំរុញឱ្យការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍
- បង្កើនមុខរបរក្នុងសហគមន៍នីមួយៗ ( ឧទាហរណ៍ ការដាំផ្សិត ការកែច្នៃអនុផលព្រៃឈើ)

**ចំណេះដឹង និង ជំនាញថ្មីៗដែលត្រូវការបន្ទាន់ និង ចាំបាច់ដើម្បីឱ្យដំណើរការបង្កើត និង គ្រប់គ្រងព្រៃឈើសហគមន៍មានប្រសិទ្ធភាព**

- ជំនាញសារពើភ័ណ្ឌព្រៃឈើ
- ជំនាញសំរបសំរួលដោះស្រាយទំនាស់

- ការទប់ស្កាត់ភ្លើងឆេះព្រៃ
- ជំនាញ និងចំណេះដឹងធ្វើផែនការគ្រប់គ្រងព្រៃសហគមន៍
- ជំនាញរៀបចំថ្នាលបណ្ដុះ
- ជំនាញចិញ្ចឹមសត្វ
- ជំនាញគ្រប់គ្រងថវិកា និងស្វែងរកថវិកា
- ចំណេះដឹងពីច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធវិស័យព្រៃឈើ
- ការស្វែងរកទីផ្សារសម្រាប់ផលិតផលរបស់សហគមន៍
- ជំនាញកែច្នៃផល-អនុផលព្រៃឈើ
- ចំណេះដឹងក្នុការបង្ក្រាប និងទប់ស្កាត់បទល្មើសព្រៃឈើ និងសត្វព្រៃ ។

## ក្រុម ៥ : ការអភិវឌ្ឍន៍សមត្ថភាព និងការស្រាវជ្រាវ

ក្រុមមានសមាជិកចំនួន ១២ នាក់ តំណាងដោយ លោក **ជា ភ័ណ្ឌ** មកពីសហគមន៍ក្រាំងស្គារ ខេត្ត កំពង់ឆ្នាំង ឡើងធ្វើបទបង្ហាញលទ្ធផលដែលក្រុមបានពិភាក្សាលើប្រធានបទ :

**ពីទស្សនៈរបស់យើង តើគួរមានការគាំទ្របែបណាខ្លះ ដើម្បីជួយដល់សកម្មភាពគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន?**

- ផ្ដល់ឯកសារពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់
- មានការលើកទឹកចិត្តដើម្បីការចូលរួម
- ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលពីវិធីសាស្ត្រជាក់ស្ដែង
- ជួយរៀបចំបង្កើតសហគមន៍ព្រៃឈើឱ្យទទួលបានការទទួលស្គាល់ពេញលេញពីផ្លូវច្បាប់
- ជួយជាថវិកា ឧបករណ៍ និងសំភារៈដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃសហគមន៍
- ទទួលយកមតិយោបល់ពីមន្ត្រីថ្នាក់ក្រោមដើម្បីពិចារណា
- ជួយធ្វើយ៉ាងណាបង្កើតការងារជូនសហគមន៍មូលដ្ឋាន
- បង្កើតប្តូរមុខរបរដែលមិនពឹងអាស្រ័យខ្លាំងលើផល-អនុផលព្រៃឈើ
- ជ្រើសរើសពូជណាដែលមានសារៈសំខាន់ មានតំលៃទីផ្សារ និងងាយផលិត
- ថ្នាល់លើត្រូវចុះជួយដោះស្រាយថ្នាក់មូលដ្ឋាន។

**តើត្រូវធ្វើដូចម្ដេចដើម្បីឱ្យការបណ្ដុះបណ្ដាលមានប្រយោជន៍សំរាប់មូលដ្ឋាន?**

- អ្នកសំរបសំរួលត្រូវមានឫកពារ អាកប្បកិរិយា ដូចអ្នកសហគមន៍ បង្ហាញភាពស្និទ្ធស្នាល
- ត្រូវមានពេលវេលាសមស្រប និងថវិកាជួយឧបត្ថម្ភពួកគាត់

- o ត្រូវស្វែងយល់ឱ្យបានច្បាស់លាស់ពីតំរូវការសំរាប់មូលដ្ឋាន
- o ត្រូវបណ្តុះបណ្តាលសហគមន៍ដោយផ្ទាល់ ឬរៀបចំជាទស្សនៈកិច្ចសិក្សា
- o ត្រូវបណ្តុះបណ្តាលតាមបែបសាមញ្ញ និងតាមភាសារ ឬចិត្តសាស្ត្ររបស់សហគមន៍

**តើកម្មវិធីផ្សព្វផ្សាយអ្វីខ្លះដែលសំខាន់សំរាប់មូលដ្ឋាន?**

- ជ្រើសរើសប្រធានបទផ្សព្វផ្សាយដែលឆ្លុះបញ្ចាំងបញ្ហាជាក់ស្តែងរបស់សហគមន៍
- ផ្សព្វផ្សាយពីសារៈសំខាន់នៃព្រៃឈើ
- ផ្សព្វផ្សាយអំពីច្បាប់ ការកែច្នៃផល-អនុផលព្រៃឈើ
- ត្រូវមានការផ្សព្វផ្សាយពីកម្មវិធីអភិវឌ្ឍន៍ជីវភាព
- ត្រូវផ្សព្វផ្សាយបណ្តុះបណ្តាលគំនិតដល់កុមារ និងយុវជន និងគ្រូ នៅតាមសាលារៀន

**តើវិធីសាស្ត្រផ្សព្វផ្សាយបែបណាខ្លះដែលមានប្រសិទ្ធភាពដល់មូលដ្ឋាន?**

- ផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ រូបភាព ការប្រមូលផ្តុំជាការប្រជុំ រឿងកំប្លែង ខ្សែភាពយន្ត ទស្សនាវដ្តី
- ផ្សព្វផ្សាយតាមប្រព័ន្ធអប់រំជាតិ
- ផ្សព្វផ្សាយតាមរយៈអាជ្ញាធរ និងសហគមន៍មូលដ្ឋាន

**តើត្រូវមានការស្រាវជ្រាវវិស័យព្រៃឈើអ្វីខ្លះដែលសំខាន់សំរាប់មូលដ្ឋាន?**

- ការស្រាវជ្រាវពីបច្ចេកទេសកែច្នៃអនុផលព្រៃឈើ ការដាំដុះអនុផលព្រៃឈើ និងជួយស្វែងរកទីផ្សារសំរាប់លក់ផលិតផល
- ស្រាវជ្រាវអំពីទស្សនៈ គំនិតការយល់ឃើញ និងទំនោររបស់មូលដ្ឋាន
- ស្រាវជ្រាវប្រភេទអនុផលព្រៃឈើដែលមានតំលៃសំរាប់ទីផ្សារ
- ស្រាវជ្រាវអំពីប្រភេទសត្វ និងរុក្ខជាតិដែលផ្តល់ផលរយៈពេលខ្លីដល់មូលដ្ឋាន
- ការស្រាវជ្រាវប្រភេទឈើក្នុងស្រុកដែលរងការគំរាមកំហែងជិតផុតពូជ

**តើគួររៀបចំប្រព័ន្ធវិញ្ញាបនប័ត្រព្រៃឈើបែបណាដែលមានប្រយោជន៍សំរាប់មូលដ្ឋាន?**

- គួរយកប្រព័ន្ធ FSC ដោយមានការពិគ្រោះយោបលជាមួយសហគមន៍មូលដ្ឋាន
- គួរជ្រើសរើសយកប្រព័ន្ធដូចប្រទេសជិតខាង និងអំណោយផលដល់សហគមន៍
- ចេញវិញ្ញាបនប័ត្រព្រៃឈើដល់សហគមន៍ព្រៃឈើណាដែលគ្រប់គ្រងព្រៃឈើបានល្អ
- លើកទឹកដល់ការកែច្នៃដើម្បីកាត់បន្ថយការដក់ហូតផល-អនុផលព្រៃឈើ

## ក្រុម ៦ : ឯកសារគោលនៃកម្មវិធីព្រៃឈើជាតិ

អ្នកចូលរួមពិភាក្សាមានចំនួន ២៣ នាក់ តំណាងឡើងធ្វើបទបង្ហាញគឺ លោកស្រី **កង គឿន** មកពីសហគមន៍ ហើយក្រុមបានពិភាក្សាលើប្រធានបទ :

**១- មាតិការឿងនៃ ឯកសារគោលកម្មវិធីព្រៃឈើជាតិ តើមានចំណុចខ្វះខាតអ្វីខ្លះ?**

- បន្ថែមគោលដៅក្នុងសេចក្តីផ្តើម

**២- ក្នុងកម្មវិធីព្រៃឈើជាតិ មានកម្មវិធីហៅថា ប្រព័ន្ធពតិមានដើម្បី ជួយគាំទ្រដល់ការត្រួតពិនិត្យ និងវាយតំលៃការអនុវត្តឱ្យមានប្រសិទ្ធភាព**

២.១. តើភាគីពាក់ព័ន្ធនៅមូលដ្ឋានអាចចូលរួមតាមដាន និងវាយតំលៃការអនុវត្តកម្មវិធីព្រៃឈើជាតិបានយ៉ាងដូចម្តេច?

- គួរមានសិក្ខាសាលាវាយតំលៃលទ្ធផលថ្នាក់ជាតិ
- គួរមានសិក្ខាសាលាវាយតំលៃ ថ្នាក់មូលដ្ឋាន (ឃុំ ស្រុក) រយៈពេល ២ឆ្នាំម្តង
- គួរមានសិក្ខាសាលាវាយតំលៃ ដោយក្រុមវាយតំលៃឯករាជ្យ

២.២. តើអ្វីខ្លះដែលអាចយកមកធ្វើជា សូចនាករ សំរាប់តាមដានវាយ តំលៃការអនុវត្តកម្មវិធីព្រៃឈើជាតិ?

- របាយការណ៍ភាពរីកចំរើន
- មានផែនការសកម្មភាព
- ការចូលរួមក្នុងវិស័យព្រៃឈើ

**៣- តំបន់ព្រៃសម្បទានដែលបានផ្អាក គួរត្រូវគ្រប់គ្រងយ៉ាងណា?**

គួរធ្វើការសិក្សាវាយតំលៃ ដើម្បីរៀបចំផែនការគ្រប់គ្រងឱ្យបានសមស្របដែលក្នុងនោះរួមមានការគ្រប់គ្រងតាមបែប :

- ព្រៃសម្បទាន
- ព្រៃអភិរក្ស
- ព្រៃសហគមន៍ និង ឥណទាន កាបោន
- ព្រៃគុបក្នុងស្រុក
- ពិនិត្យ និងកែសំរួលកិច្ចសន្យា និង លក្ខណ្ឌនៃការរៀបចំ ផែនការគ្រប់គ្រងព្រៃសម្បទានដែលបានផ្អាក

**៤- តើកម្មវិធីព្រៃឈើជាតិ អាចជួយដោះស្រាយទំនាស់ដែលអាចកើត ចេញពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចយ៉ាងណា ខ្លះ? (ការងារអ្វីខ្លះដែលត្រូវ/គួរធ្វើក្នុងការអនុវត្ត កម្មវិធីព្រៃឈើជាតិ)**

**មុនផ្តល់ដីសម្បទានសេដ្ឋកិច្ច :**

- គួរមានការផ្សព្វផ្សាយឱ្យបាន ទូលំទូលាយដល់ភាគីពាក់ព័ន្ធ
- ត្រូវផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ និង ផែនការអភិវឌ្ឍន៍ របស់ក្រុមហ៊ុន

- ការផ្តល់គួរមានទំហំសមស្រប,

**ក្រោយផ្តល់ដីសម្បទានសេដ្ឋកិច្ច :**

- តំរូវឱ្យក្រុមហ៊ុនបោះបង្គោលព្រំ
- គួរមានការត្រួតពិនិត្យ និងវាយតំលៃលើការអនុវត្តផែនការអភិវឌ្ឍន៍របស់ក្រុមហ៊ុនពីស្ថាប័នជំនាញ